# យុត្តិធម៌សម្រាប់ប្រជានេសាទ៖

## ប្រជាជននេសាទលក្ខណៈគ្រួសារប្រឈមមុខនឹងជីវិតប្រចាំថ្ងៃ

**ស្រាវជ្រាវ និង ចងក្រង៖**

ស្រេង ករុណា, យន់ ឃីម
យ៉ោន ចំរើន, លុច លេខ និង
ស្រេង លីដា



# អំពីការស្រាវជ្រាវ

ការស្រាវជ្រាវចំពោះប្រធានបទ «**យុត្តិធម៌សម្រាប់ប្រជានេសាទ៖ ប្រជាជននេសាទលក្ខណៈគ្រួសារប្រឈមមុខនឹងជីវិតប្រចាំថ្ងៃ**» គឺជាការហ្វឹកហាត់សម្រាប់ក្រុមអ្នកស្ម័គ្រចិត្តរបស់យើងទាំង៥នាក់ រៀនសូត្រអំពីការស្រាវជ្រាវមួយឲ្យសមស្របទៅតាមបទដ្ឋានឧត្តមសិក្សាប្រកបដោយគុណភាព។ ការស្រាវជ្រាវមួយនេះ ចងក្រងឡើងមិនទាន់ឆ្លើយតបទៅតាមប្រធានបទឲ្យបានពេញលេញនោះទេ។ ក្រុមអ្នកស្ម័គ្រចិត្តរបស់យើង សូមចែករំលែកបទពិសោធន៍ការស្រាវជ្រាវនេះ ដល់មិត្តអ្នកអានទាំងអស់ដែលមានបំណងចង់សិក្សាពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងស្វែងយល់បន្ថែមពីជីវិតរបស់ប្រជាជននៅតំបន់អូរស្វាយ ក្នុងខេត្តស្ទឹងត្រែង។

**សូមគោរពអរគុណ**



*ក្រុមគ្រួសារអ្នកនេសាទកំពុងដោះត្រីចេញពីមង។ (រូបថត៖ ស្រេង លីដា)*

# សេចក្ដីសង្ខេប

ប្រទេសកម្ពុជា ចាប់ផ្ដើមមានកំណើនផលិតផលក្នុងស្រុក សរុបចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បានដួលរលំនៅឆ្នាំ១៩៧៩ ដោយសារតែការផ្លាស់ប្ដូរសេដ្ឋកិច្ចផែនការទៅជាទីផ្សារសេរីរបស់រដ្ឋាភិបាលគ្រប់គ្រងថ្មី។ ភាគច្រើននៃកំណើនផលិតផលក្នុងស្រុកសរុបនោះ បានកើតឡើងនៅក្នុងវិស័យឧស្សាហកម្មវាយនភណ្ឌ និងទេសចរណ៍ ប៉ុន្តែវិស័យកសិកម្ម និងការនេសាទ នៅតែជាប្រភពចម្បងនៃអាហារ និងប្រាក់ចំណូលសម្រាប់ប្រជាជនភាគច្រើនដែលរស់នៅតាមទីជនបទ[១]។ អង្ករ និងត្រី ស្ថិតក្នុងចំណោមការនាំចេញរបស់ប្រទេសកម្ពុជា ដែលរួមចំណែកដល់កំណើនផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា ក៏ដូចជាប្រភពអាហារសំខាន់ៗសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាជនទូទៅ។ ជីវិតរបស់ប្រជាជនកម្ពុជាជាច្រើន រស់នៅពឹងផ្អែកលើទន្លេមេគង្គ ដែលទន្លេនេះមានប្រភពមកពីប្រទេសចិន ហូរចុះមកតាមដងទន្លេមេគង្គ កាត់ប្រទេសមីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម។ ទោះជាយ៉ាងណាក៏ដោយ គម្រោងទំនប់វារីអគ្គិសនីទាំងខ្នាតធំ និងតូច បានកើនឡើងនៅតាមដងទន្លេមេគង្គ ដែលប្រហែលជាប្រភពនៃផលប៉ះពាល់ ថែមទាំងមានកត្តាផ្សេងៗទៀតបានបង្កឡើងនៅតាមមូលដ្ឋានផ្ទាល់ រួមមាន ការចាប់ត្រីខុសច្បាប់ ប្រសិទ្ធភាពនៃការអនុវត្តច្បាប់នេសាទ និងការហិនហោចជម្រកត្រី ដែលជាមូលហេតុចម្បងធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានដល់សហគមន៍កម្ពុជាដែលរស់នៅពឹងផ្អែកលើទន្លេមេគង្គ។ នៅក្នុងចំណោមប្រជាជនរស់នៅតាមដងទន្លេមេគង្គដែលកំពុងតែរងផលប៉ះពាល់ក៏មានប្រជាជនដែលរស់នៅពឹងផ្អែកលើរបរនេសាទសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃនៅតំបន់អូរស្វាយ កំពុងតែត្អូញត្អែរពីផលលំបាកពីការរកត្រីមិនបានដើម្បីចិញ្ចឹមជីវិតដូចពីមុន។ លើសពីនេះ ប្រជាជនជាច្រើនដែលរស់នៅលើកោះទាំង ៨ នៅស្រុកបុរីអូរស្វាយសែនជ័យ បានបង្ហាញពីក្ដីបារម្ភចំពោះសុវត្ថិភាពក្នុងការរស់នៅប្រចាំថ្ងៃក្រោមទំនប់វារីអគ្គិសនី ។

គម្រោងទំនប់វារីអគ្គិសនីជាច្រើនមានទីតាំងនៅក្នុងប្រទេសចិន និងសាងសង់នៅប្រទេសតាមដងទន្លេមេគង្គ។ ចំណែកប្រទេសនៅក្រោមដងទន្លេមេគង្គផ្សេងទៀត រួមទាំងប្រទេសកម្ពុជាដែរ បានចូលរួមលើការវិនិយោគនេះ ព្រោះមានគោលបំណងធ្វើសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ី។

១ NOVAsia Contributor, “The Mekong River – Environment and Economic Impacts of Dam Building in Southeast Asia,” NovAsia, January 12,2022, https://novasiagsis.com/the-mekong-river-environment-and-economic-impacts-of-dam-building-in-southeast-asia/.

# គោលបំណងនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវរបស់ក្រុមអ្នកស្ម័គ្រចិត្តយើងនឹងស្វែងយល់ពីស្ថានភាពជាក់ស្តែងដែលកំពុងតែកើតមានឡើងចំពោះអ្នកនេសាទរស់នៅតាមដងទន្លេមេគង្គនៅតំបន់អូរស្វាយ ថាតើអ្នកនេសាទកំពុងតែមានជីវិតបែបណា បន្ទាប់ពីមានការលើកឡើងពីបញ្ហាយ៉ាងច្រើនទាក់ទងនឹងការអភិវឌ្ឍតាមដងទន្លេមេគង្គ។ ទោះបីជាមានការអន្តរាគមន៍ពីការសាងសង់ទំនប់វារីអគ្គិសនី និងមានការរិះគន់ពីអ្នកជំនាញយ៉ាងណាក៏ដោយ ក៏បញ្ហាដែលបានកើតឡើងចេញពីទំនប់វារីអគ្គិសនី ដែលបានសាងសង់រួចនៅតាមដងទន្លេមេគង្គ នៅតែបន្តប៉ះពាល់ដល់ជីវិតរបស់ប្រជាជនមួយចំនួន ដែលរស់នៅពឹងផ្អែកលើរបរនេសាទដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃនៅតំបន់អូរស្វាយ។ ប្រជាជនខ្មែរប្រហែល ៥ លាននាក់ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម[២] ភាគច្រើនបានជួបប្រទះជោគវាសនាអាក្រក់នៅក្នុងរបបខ្មែរក្រហម ក្នុងនោះមានប្រជាជនដែលកំពុងរស់នៅតំបន់អូរស្វាយដែរ។ សព្វថ្ងៃនេះ ប្រជាជននៅតំបន់អូរស្វាយ បានបន្តប្រឈមមុខដោះស្រាយបញ្ហាដែលប៉ះពាល់ពីការអភិវឌ្ឍកើតចេញពីការសាងសង់ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេគង្គ ។

កិច្ចការស្រាវជ្រាវនេះ ចាប់ផ្តើមដំបូងដោយមើលទៅលើរឿងរ៉ាវទូទៅ និងជីវិតរស់នៅរបស់ប្រជាជននៅតំបន់អូរស្វាយ ដែលរស់នៅពឹងផ្អែកលើទន្លេមេគង្គ តាំងពីដើមរហូតមកដល់សព្វថ្ងៃនេះ។ នៅក្នុងកិច្ចការស្រាវជ្រាវនេះ យើងក៏បង្ហាញអំពីរបៀបដែលយើងរៀបរាប់សាច់រឿងវិធីសាស្រ្តស្រាវជ្រាវ អ្នកចូលរួមក្នុងកិច្ចការស្រាវជ្រាវ របៀបដែលយើងវិភាគទិន្នន័យ ការចងក្រងសាច់រឿងរបស់អ្នកភូមិផ្សេងៗទៀត និងសេចក្តីសន្និដ្ឋានចេញពីការវិភាគទិន្នន័យរបស់យើង។ នៅក្នុងសេចក្តីសន្និដ្ឋាន យើងនឹងពិភាក្សាថា តើប្រជាជនកំពុងជួបបញ្ហាអ្វីខ្លះ? តើបញ្ហានោះបានដោះស្រាយដែរឬទេ? ហើយថា តើបញ្ហាដែលបានកើតឡើងនោះ ត្រូវបានដោះស្រាយយ៉ាងដូចម្តេចដែរ? ឬមានអ្វីដែលមិនទាន់បានដោះស្រាយ? នៅក្នុងកិច្ចការស្រាវជ្រាវ យើងក៏រៀបរាប់ពីសាច់រឿងរបស់ប្រជាជនដែលរស់នៅតំបន់អូរស្វាយផ្សេងៗទៀត។ យើងសម្រេចចិត្តរៀបរាប់អំពីសាច់រឿងរបស់ប្រជាជនផ្សេងទៀតនៅក្នុងកិច្ចការស្រាវជ្រាវ ព្រោះសាច់រឿងរបស់ប្រជាជនដែលបានឆ្លងកាត់បញ្ហាជាច្រើនជំនាន់យ៉ាងដូច្នេះ គឺជាមតិយោបល់យ៉ាងសំខាន់សម្រាប់ឆ្លុះបញ្ចាំងអំពីតថភាពជីវិតរស់នៅរបស់ប្រជាជននៅតំបន់អូរស្វាយបន្ថែមទៀត។

២ "ALTHOUGH TWO MILLION WERE KILLED, FIVE MILLION SURVIVED TO TELL THEIR STORY," មជ្ឈមណ្ឌលឯកសារកម្ពុជា, accessed May 31, 2024, https://www.dccam.org/although -two-millions-were-killed-five-millions-more-survived-to-tell-their-story-the-perpetrators-of-these-crimes-also-survived-as-well/.



*ក្រុមនិស្សិត និងគ្រូពេទ្យស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកបុរីអូរស្វាយសែនជ័យ។ (រូបថត៖ ស្រេង លីដា)*

ប្រធានបទជាច្រើនបានសរសេរឡើងទាក់ទងនឹងផលប៉ះពាល់របស់ទំនប់វារីអគ្គិសនីមកលើប្រជាជនរស់នៅតាមដងទន្លេមេគង្គ។ ក្រុមអ្នកស្ម័គ្រចិត្តរបស់យើង ក៏បានលើកយកប្រធានបទ **«យុត្តិធម៌សម្រាប់ប្រជានេសាទ៖ ប្រជាជននេសាទលក្ខណៈគ្រួសារប្រឈមមុខនឹងជីវិតប្រចាំថ្ងៃ»** ជាបញ្ហាមួយកំពុងប៉ះពាល់មកលើប្រជាជនកម្ពុជា ដែលអាស្រ័យផលពីទន្លេមេគង្គ មកធ្វើការស្រាវជ្រាវ ប៉ុន្តែប្រធានបទរបស់យើង គឺពឹងផ្អែកទាំងស្រុងទៅលើសាច់រឿងជាក់ស្តែងរបស់ប្រជាជនដែលរស់នៅតាមដងទន្លេមេគង្គ ក្នុងតំបន់អូរស្វាយ។ សាច់រឿងរបស់ប្រជាជនដែលយើងបានជ្រើសរើស មិនទាន់បានចែករំលែកទូលំទូលាយនៅឡើយទេ ហើយការសិក្សាស្រាវជ្រាវរបស់យើងមានលក្ខណៈលម្អិត ដើម្បីបំពេញនូវចន្លោះខ្វះខាតរបស់អ្នកស្រាវជ្រាវផ្សេងទៀត។

យើងធ្វើការសិក្សាស្រាវជ្រាវលើប្រធាននេះ ដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅពីបញ្ហារបស់ប្រជាជននៅក្នុងតំបន់ពីការនេសាទ និងកត្តាផ្សេងៗ ដែលជាមូលហេតុពិតប្រាកដនៃការបំផ្លាញត្រី និងដើមឈើ ដែល



*អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះជួបសួរសុខទុក្ខប្រជាជននៅស្រុក បុរីអូរស្វាយសែនជ័យ។ (រូបថត៖ ស្រេង លីដា)*

ធ្វើឲ្យប្រជាជនជួបការលំបាកនឹងបញ្ហារកត្រីហូបមិនបានមកទល់សព្វថ្ងៃនេះ។ មួយវិញទៀត យើងលើកយកប្រធានបទមួយនេះឡើង ដើម្បីទុកជាឯកសារសម្រាប់ឲ្យក្មេងៗជំនាន់ក្រោយបានយល់ដឹងអំពីការនេសាទរបស់អ្នកជំនាន់មុន ថាមានការនេសាទដូចម្តេចខ្លះ ហើយប្រជាជនមានជីវិតរស់ដូចយ៉ាងដូចម្តេច?

# ប្រវត្តិសាវតារ

ទន្លេមេគង្គ គឺជាជលផលទឹកសាបដ៏ធំបំផុតនៅលើពិភពលោក (ត្រីប្រហែល ២.៣លានតោន ត្រូវប៉ាន់ប្រមាណថា ចាប់បានក្នុងមួយឆ្នាំ) និងប្រព័ន្ធទន្លេជីវចម្រុះធំបំផុតទីបី (មានត្រីប្រហែល ៨០០ប្រភេទ) បន្ទាប់ពីទន្លេអាម៉ាហ្សូន និងកុងហ្គោ[៣]។ ទន្លេមេគង្គមានភាពល្បីល្បាញដោយសារជីវចម្រុះក្នុងទឹកដែលមានសារសំខាន់សម្រាប់សង្គម សុខភាពរាងកាយ និងសេដ្ឋកិច្ចរបស់មនុស្សរាប់លាននាក់ ដែលរស់នៅតាមដងទន្លេមេគង្គ ក្នុងប្រទេសចិន មីយ៉ាន់ម៉ា ឡាវ ថៃ កម្ពុជា និងវៀតណាម។ តាំងពីបុរាណកាលមក ប្រព័ន្ធអេកូឡូស៊ីនេះ បានជួយដល់សកម្មភាពនេសាទ និងកសិកររាប់លាននាក់។ ប្រជាជនជាង ៦៥លាននាក់រស់នៅតាមអាងទន្លេមេគង្គក្រោម ដែលមានប្រជាជនប្រហែល ៤០ភាគរយ រស់នៅក្នុងចម្ងាយ ១៥គីឡូម៉ែត្រពីទន្លេមេគង្គ និងទទួលបានប្រូតេអ៊ីនប្រហែល ២.៥ លានតោន ពីទន្លេមេគង្គក្នុងមួយឆ្នាំ[៤]។ ក្នុងចំណោមប្រទេសទាំងនោះ ប្រទេសកម្ពុជា ក៏ជាប្រទេសមួយដែលមានធនធានជលផលចម្រុះធំបំផុតនៅលើពិភពលោក ដោយសារប្រព័ន្ធអេកូឡូស៊ីតែមួយគត់នៃទន្លេមេគង្គ និងបឹងទន្លេសាប បានតភ្ជាប់គ្នាដោយផ្លូវទឹក[៥]។ ទោះបីទន្លេមេគង្គអំណោយផលដល់ជីវភាពរស់នៅរបស់ប្រជាជនក៏ដោយ ក៏បណ្តាប្រទេសនៅតាមដងទន្លេមេគង្គ ដូចជា ប្រទេសចិន មីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម នៅតែបន្តស្វែងរកគោលដៅអភិវឌ្ឍន៍ចេញពីទន្លេមេគង្គ ក្នុងគោលបំណងជំរុញឲ្យមានកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។ ប្រទេសទាំងនេះ បានជ្រើសរើសវិនិយោគលើទន្លេមេគង្គដើម្បីសាងសង់ទំនប់វារីអគ្គិសនីដោយការបង្កើនថាមពលអគ្គិសនីសម្រាប់ហេតុផលអភិវឌ្ឍន៍សេដ្ឋកិច្ច។ ការអភិវឌ្ឍទំនប់វារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គ បានដំណើរការនៅភាគឦសានប្រទេសថៃ តាំងពីឆ្នាំ១៩៦៥ មកម្ល៉េះ បន្ទាប់មកមានទំនប់វារីអគ្គិសនីជាបន្តបន្ទាប់ និងចាប់ផ្តើមមានការសម្ភោធជាផ្លូវការ[៦]។ ក្រោយមក ការសាងសង់ទំនប់វារីអគ្គិសនីបានមួយចំនួនក៏ត្រូវបានផ្អាកដំណើរការមួយរយៈ។ ជម្លោះសង្គ្រាមត្រជាក់ បានរារាំងការសាងសង់ទំនប់ជាច្រើនដែលរំពឹងថានឹងសាងសង់សម្រាប់អាងទន្លេមេគង្គរវាងទសវត្សរ៍ឆ្នាំ១៩៦០ និង ១៩៨០[៧]។ នៅឆ្នាំ១៩៩០ ទំនប់ Manwan ត្រូវបានសាងសង់នៅក្នុងប្រទេសចិន[៨] ហើយមានគម្រោងសាងសង់ទំនប់ជាច្រើនទៀតនាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ១៩៩៨ ដល់ឆ្នាំ១៩៩៩ បានធ្វើឲ្យគម្រោងទំនប់វារីអគ្គិសនីជាច្រើនត្រូវលុបចោល ខណៈដែលគម្រោងសាងសង់ទំនប់ដែលកំពុងដំណើរការផ្សេងទៀតត្រូវបានពន្យារពេល ឬកាត់បន្ថយទំហំ[៩]។ ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍទំនប់វារីអគ្គិសនីនៅតែចាប់ផ្តើមនៅលើដងទន្លេមេគង្គក្នុងប្រទេសចិន។

ទន្លេមេគង្គហូរកាត់ប្រទេសចិន មីយ៉ាន់ម៉ា ឡាវ ថៃ កម្ពុជា និងវៀតណាម។ អាងទន្លេមេគង្គចែកចេញជា

៣ Intralawan, Wood & Frankel, "Economic Evaluation of Hydropower Projects in the Lower Mekong Basin," OXFAM, March 2017, P.2.

៤ Mekong River Commission For Sustainable Development, "People," MRC, 2022.

៥ ស្ទួន ។

៦ Soukhaphon, Akarath, Ian G. Baird, and Zeb S. Hogan,The Impacts of Hydropower Dams in the Mekong River Basin: A Review, Water (Basel), 13, No. 3, p.2.

៧ ស្ទួន ។

៨ ស្ទួន ។

៩ Soukhaphon, Akarath, Ian G. Baird, and Zeb S. Hogan,The Impacts of Hydropower Dams in the Mekong River Basin: A Review, Water (Basel), 13, No. 3, p.2.



*អ្នកនេសាទកំពុងតែដាក់មងចាប់ត្រីក្នុងទន្លេមេគង្គ ស្រុកបុរីអូរស្វាយសែនជ័យ។ (រូបថត៖ ស្រេង លីដា)*

ពីរអាង គឺអាងទន្លេមេគង្គលើ សំដៅលើតំបន់អាងទន្លេមេគង្គក្នុងទឹកដីនៃប្រទេសចិន និងមីយ៉ាន់ម៉ា ចំណែកអាងទន្លេមេគង្គក្រោម សំដៅទៅលើតំបន់អាងទន្លេមេគង្គនៅក្នុងទឹកដីប្រទេសឡាវ ថៃ កម្ពុជា និងវៀតណាម។ អាងទន្លេមេគង្គលើ មានប្រហែល ៣០ ភាគរយនៃទីតាំងអាងទាំងមូល និងមានប្រជាជនរស់នៅតាមដងទន្លេប្រហែល ១៥លាននាក់[១០]។ ចំណែកអាងទន្លេមេគង្គក្រោម ស្មើនឹង៧០ភាគរយ ដែលនៅសល់នៃទីតាំងអាងទន្លេមេគង្គ និងមានប្រជាជនប្រហែល ៦០លាននាក់ រស់នៅតាមដងទន្លេមេគង្គក្រោម[១១]។

នៅទសវត្សរ៍ឆ្នាំ ២០១០ ការអភិវឌ្ឍទំនប់បានកើនឡើងយ៉ាងខ្លាំង ហើយមានការសាងសង់ទំនប់ជាបន្តបន្ទាប់នៅក្នុងប្រទេសឡាវ ចិន និងប្រទេសកម្ពុជា។ គម្រោងវារីអគ្គិសនីធំៗចំនួន១២ ដែលស្នើឡើងនៅតាមដងទន្លេមេគង្គ គឺនៅក្នុងប្រទេសឡាវ ជាប់ព្រំដែនឡាវ-ថៃ-កម្ពុជា[១២]។ ការសាងសង់ទំនប់វារីអគ្គិសនីតាមដងទន្លេមេគង្គ បានក្លាយជាក្តីកង្វល់យ៉ាងខ្លាំងសម្រាប់ប្រជាជនដែលរស់នៅពឹងផ្អែកលើធនធានធម្មជាតិនៃទន្លេមេគង្គ។ សហគមន៍បានផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដល់រដ្ឋាភិបាល ម្ចាស់ជំនួយ អ្នកវិនិយោគ និងសង្គមស៊ីវិល ទាក់ទងនឹងបញ្ហាដែលបង្កឡើងដោយទំនប់វារីអគ្គិសនី[១៣]។ ការសាងសង់ទំនប់វារីអគ្គិសនីហាក់ដូចជានៅតែបន្តជះឥទ្ធិពលអវិជ្ជមានរហូតដល់សព្វថ្ងៃទៅលើប្រជាជនកម្ពុជា ដែលរស់នៅអាស្រ័យផលលើទន្លេមេគង្គ ដូចជា ប្រជាជនរស់នៅស្រុកបុរីអូរស្វាយសែនជ័យ ជាពិសេសប្រជាជនដែលរស់នៅលើកោះទាំង៨ ដែលមិនសូវមានឱកាសក្នុងការប្រកបមុខរបរផ្សេងៗដ៏ទៃទៀត។



*ទិដ្ឋភាពព្រៃលិចទឹកក្នុងទន្លេមេគង្គ ស្រុកបុរីអូរស្វាយសែនជ័យ។ (រូបថត៖ ស្រេង លីដា)*

---

១០ MRC (Mekong River Commission), State of the Basin Report, MRC, April 2010, P.31.

១១ ស្អួន ។

១២ International Centre for Environmental Management (ICEM), Strategic Environmental Assessment of Hydropower on the Mekong Mainstream: a summary of the final Report, October, 2010, P.4.

១៣ អ៊ុក សាវបូរី, "ផលប៉ះពាល់ដោយគម្រោងសង់ទំនប់វារីអគ្គិសនីចំពោះពលរដ្ឋតាមដងទន្លេមេគង្គ," វិទ្យុអាស៊ីសេរី,ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣។ https://www.rfa.org/khmer/news/environment/impact-of-environment -by-hydropower-dam-06052013041732.html.

# អំពីស្រុកបុរីអូរស្វាយសែនជ័យ




*អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមសង្ក្រាន្តឆ្នាំថ្មី នៅស្រុកបុរីអូរស្វាយសែនជ័យ។ (រូបថត៖ ស្រេង លីដា)*

ស្រុកបុរីអូរស្វាយសែនជ័យ គឺជាស្រុកមួយក្នុងចំណោមស្រុកទាំងប្រាំមួយក្នុងខេត្តស្ទឹងត្រែង មានព្រំប្រទល់ជាប់នឹងស្រុកសៀមប៉ាង និងស្រុកសេសាន ខាងលិចជាប់ស្រុកថាឡាបរិវ៉ាត់ ខាងជើងជាប់ព្រំប្រទល់កម្ពុជា-ឡាវ និងខាងត្បូងជាប់នឹងក្រុងស្ទឹងត្រែង។ ស្រុកនេះជាស្រុកវ័យក្មេង ដែលទើបតែប្រកាសដាក់ឲ្យដំណើរការនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩។ យោងតាមរបាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ ប្រចាំខែមករា ឆ្នាំ ២០២៤ សព្វថ្ងៃនេះ ស្រុកបុរីអូរស្វាយសែនជ័យមាន ៣ឃុំ និង ១៨ភូមិ មានប្រជាជនចំនួន ៤,៣៧៧ គ្រួសារ និងប្រជាជនសរុបចំនួន ១៩,៣៦៥នាក់។ ប្រជាជនដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើងមានចំនួន ១១,១៦៣នាក់ ស្រីចំនួន ៥,៨០២នាក់ គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤។ ប្រជាជននៅស្រុកបុរីអូរស្វាយសែនជ័យ ប្រមាណជាង ៨៨ ភាគរយ រស់នៅពឹងផ្អែកលើវិស័យកសិកម្ម និងនេសាទត្រី ក្រៅពីនោះ ក្រុមគ្រួសារខ្លះធ្វើជាកម្មកររកស៊ីជួញដូរ បុគ្គលិកក្រុមហ៊ុន អង្គការ និងមន្ត្រីរាជការសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ។

ស្រុកបុរីអូរស្វាយសែនជ័យ ជាតំបន់ប្រវត្តិសាស្ត្រយៃចំណាស់ និងបានឆ្លងកាត់ជាច្រើនសម័យកាល។ កេ ឈុំ កេទប្រុស អាយុ ៧០ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង បានលើកឡើងថា កាលពីដើមទសវត្សរ៍៦០ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ចាប់ផ្តើមកៀងគរប្រជាជនឲ្យមករស់នៅតំបន់អូរស្វាយ ដើម្បីការពារព្រំដែនប្រទេសកម្ពុជា ពីការឈ្លានពានរបស់ប្រទេសជិតខាង ហើយប្រជាជនជាច្រើននាក់បានផ្លាស់ប្តូរទីលំនៅមកពីខេត្តតាកែវ កំពង់ចាម កំពង់ធំ ភ្នំពេញ ព្រៃវែង កណ្តាល ក្រចេះ កំពង់ឆ្នាំង ព្រះវិហារ និងខេត្តផ្សេងៗទៀត ស្ម័គ្រចិត្តមករស់នៅតំបន់អូរស្វាយ តាមការអំពាវនាវរបស់ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ និងដោយសារសម្លឹងឃើញពីភាពអំណោយផលពីទន្លេមេគង្គសម្រាប់ប្រកបមុខរបរចិញ្ចឹមជីវិត។ ជាបន្តបន្ទាប់មក ប្រជាជនដែលមករស់នៅតំបន់អូរស្វាយ ទទួលបានដីធ្លី ផ្ទះសម្បែង និងការយកចិត្តទុកដាក់ពីអ្នកដឹកនាំតំបន់អូរស្វាយ។ ណាត់ សាយ បានបន្ថែមទៀតថា ប្រជាជននៅតំបន់អូរស្វាយពេលនោះ ភាគច្រើនប្រកបរបរនេសាទ ជួញដូរត្រី មិនដែលខ្វះខាតអ្វីឡើយក្នុងការចិញ្ចឹមជីវិតប្រចាំថ្ងៃ ។

ទោះបីជាតំបន់អូរស្វាយ មើលទៅហាក់បីដូចជាមានភាពអំណោយផល និងងាយស្រួលក្នុងការរស់នៅក៏ដោយ ប៉ុន្តែតំបន់នេះមានរឿងរ៉ាវជាច្រើនបានកើតឡើង។ តំបន់អូរស្វាយ បានទទួលរងនូវការញាំញីពីសង្គ្រាមដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម មិនខុសពីតំបន់ផ្សេងទៀតក្នុងប្រទេសកម្ពុជាទេ។ ណាត់ សាយ បានរៀបរាប់បន្ថែមទៀតប្រាប់ថា ៖

នៅដើមទសវត្សរ៍៧០ សង្គ្រាមរដ្ឋប្រហារបានចូលមកដល់ធ្វើឲ្យតំបន់អូរស្វាយ រងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ តាមរយៈការទម្លាក់គ្រាប់បែកខ្ទេចខ្ទីគ្មានសេសសល់។ យន្តហោះអាមេរិក បានទម្លាក់គ្រាប់បែកដោយគិតថា មានទាហានវៀតកុង មកលាក់ខ្លួននៅម្តុំទីនេះ។ ប្រជាជនរត់រកគេចខ្លួន គេចចូលរណ្តៅត្រង់សេ និងខ្លះទៀតបានគេចខ្លួនទៅតាមបណ្តាខេត្តផ្សេងៗ និងភៀសខ្លួនទៅប្រទេសឡាវ។ សង្គ្រាមនេះបានបន្សល់ទុករណ្តៅគ្រាប់បែកធំៗជាច្រើន។ បន្ទាប់មក ក្រុមខ្មែរក្រហម បានឡើងកាន់កាប់អំណាច ហើយស្ថានភាពនៅតំបន់អូរស្វាយ មិនខុសពីតំបន់ផ្សេងទៀតទេ។ ប្រជាជនរស់នៅអត់ឃ្លាន ធ្លាក់ខ្លួនឈឺ អ្នកខ្លះព្យាបាលទាន់ក៏ជា ខ្លះទៀតព្យាបាលមិនទាន់ក៏ស្លាប់បាត់បង់ជីវិត។ ប្រជាជនរស់នៅរងទុក្ខវេទនា គ្មានសិទ្ធិសេរីភាព និងបែកបាក់មនុស្សជាទីស្រលាញ់។

បន្ទាប់ពីសង្គ្រាមបានផុតរលត់ទៅនៅឆ្នាំ១៩៧៩ ប្រជាជនជាច្រើននាក់ដែលបន្តរស់នៅតំបន់អូរស្វាយ បានខិតខំកសាងស្រុកភូមិ និងដោះស្រាយជីវភាពរស់នៅពីបាតដៃទទេឡើងវិញ។ ការកសាងជីវិតឡើងវិញមិនងាយស្រួលទេ សម្រាប់ប្រជាជនកម្ពុជាដែលទទួលរងការញាំញីពីសង្គ្រាម។ ទោះបីជាយ៉ាងណា ប្រជាជននៅតំបន់អូរស្វាយនៅតែមានសំណាង បានរស់នៅលើទឹកដីមួយដែលអំណោយផលខាងកសិកម្ម និងទទួលបានប្រូតេអ៊ីនពីត្រីយ៉ាងសម្បូរបែប។ មិនយូរប៉ុន្មាន ការសាងសង់ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេគង្គ និងការអនុវត្តច្បាប់មិនមានប្រសិទ្ធភាពចំពោះការចាប់ត្រី បានក្លាយជាក្តីកង្វល់ដល់ប្រជាជនយ៉ាងខ្លាំង។ រហូតដល់សព្វថ្ងៃ ទង្វើទាំងអស់នេះបានជះឥទ្ធិពលដល់ការរស់នៅរបស់ប្រជាជនបន្តិចម្តងៗ និងឲ្យបន្តដោះស្រាយជារៀងរាល់ថ្ងៃ។ ប្រជាជនជាច្រើនបានត្អូញត្អែរពីការបាត់បង់ធនធានត្រី បាត់បង់ជម្រកត្រី លំហូរទឹកមិនទៀងទាត់ការបង្កជាគ្រោះថ្នាក់ និងការអនុវត្តច្បាប់ចាប់ត្រីដែលជាផ្នែកមួយនៃក្តីបារម្ភរបស់ប្រជាជន។ អ្នកនេសាទជំពាក់បំណុលច្រើន ដោយសារអ្នកនេសាទមិនអាចចាប់ត្រីបានគ្រប់គ្រាន់តាមតម្រូវការប្រចាំថ្ងៃ ហើយបញ្ហាទាំងអស់នេះ បានបង្ខំឲ្យសមាជិកក្នុងគ្រួសារត្រូវចាកចេញពីផ្ទះទៅស៊ីឈ្នួលនៅតំបន់ផ្សេង ឬប្រទេសជិតខាង[១៤]។

---

១៤ ខាន់ សុគុំមនោ, អ្នកនិពន្ធ Abby Seiff៖ «យើងគួរនៅមានសង្ឃឹមថា បញ្ហាបឹងទន្លេសាបនឹងអាចប្រសើរឡើងវិញ,» វីអូអេ, ២២ មេសា ២០២២។ https://khmer.voanews.com/a/there-are-reasons-to-be-hopeful -if-things-come-together-well-and-if-mekong-river-countries-can-work-together-/6539538 . html

# មូលហេតុដែលក្រុមរបស់យើងរៀបរាប់សាច់រឿង

នៅពេលដែលក្រុមអ្នកស្ម័គ្រចិត្តរបស់យើងទៅដល់តំបន់អូរស្វាយជាលើកដំបូងក្នុងនាមជាអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានសមាជិកក្នុងក្រុមម្នាក់ឈ្មោះ ស្រេង លីជា ភេទប្រុស ដែលជានិស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រស់នៅតំបន់អូរស្វាយផ្ទាល់ បានរៀបរាប់ពីតំបន់អូរស្វាយថា តំបន់អូរស្វាយកំពុងតែរងគ្រោះពីទំនប់វារីអគ្គិសនី ដែលបានសាងសង់នៅក្នុងប្រទេសឡាវ ឈ្មោះទំនប់ដនសាហុង។ ក្រៅពីនោះ បញ្ហាប្រឈមដែលក្រុមអ្នកស្ម័គ្រចិត្តរបស់យើងបានឮចេញពីសហគមន៍ គឺមិនមែនតែបញ្ហាទំនប់វារីអគ្គិសនីមួយទេ ប៉ុន្តែមានបញ្ហាមួយចំនួនទៀត រួមមានលំហូរទឹកមិនប្រក្រតី បញ្ហាហិនហោចត្រី ដើមឈើក្នុងទឹកដែលជាជម្រកត្រីបានងាប់ជាបន្តបន្ទាប់ ការអនុវត្តច្បាប់[15] ដែលកត្តាទាំងអស់នេះ កំពុងតែផ្ដល់ផលរំខានដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅស្រុកបុរីអូរស្វាយសែនជ័យ។ បន្ទាប់ពីបានឮការលើកឡើងរបស់សមាជិកក្រុម ក្រុមអ្នកស្ម័គ្រចិត្តយើង ក៏បានពិនិត្យមើលឃើញថា មានអ្នកស្រាវជ្រាវជាច្រើននាក់ បានធ្វើការស្រាវជ្រាវជុំវិញបញ្ហាទាំងអស់នេះនៅតំបន់អូរស្វាយដែរ ប៉ុន្តែនៅមានការខ្វះចន្លោះច្រើន ជាពិសេស បញ្ហាដែលកើតមានឡើងនៅក្នុងមូលដ្ឋានផ្ទាល់ ។

ក្រោយមក ក្រុមអ្នកស្ម័គ្រចិត្តរបស់ខ្ញុំ មានឱកាសបានធ្វើបទបង្ហាញអំពីប្រធានបទមួយទាក់ទងទៅនឹងទំនប់វារីអគ្គិសនីទៅកាន់អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាច្រើននាក់ ប៉ុន្តែមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ។ បន្ទាប់ពីបានដឹងព័ត៌មានខ្លះៗ ថែមទាំងឮប្រជាជននៅក្នុងភូមិបានត្អូញត្អែរពីបញ្ហារកត្រីមិនបានសូម្បីត្រឹមតែយកមកហូបប្រចាំថ្ងៃ យើងក៏ចាប់ផ្ដើមមានគំនិតសរសេរកិច្ចការស្រាវជ្រាវនេះឡើង។ មិនតែប៉ុណ្ណោះ ប្រជាជនមួយចំនួន មិនបានដឹងថាតើបញ្ហាទាំងអស់នេះកើតឡើងដោយសារអ្វីនោះទេ។ ប្រជាជនមួយចំនួនតែងតែត្អូញត្អែរពីចំណាត់ការរបស់អាជ្ញាធរចំពោះសកម្មភាពចាប់ត្រីមកបរិភោគលក្ខណៈគ្រួសារថាតឹងរ៉ឹងខុសពីមុន ហើយត្រីនៅតែបន្តហិនហោច។ ទោះបីជាយ៉ាងដូចច្នេះក្ដី ប្រជាជនហាក់បីដូចជាមិនសូវដឹងថាតើមូលហេតុអ្វីបានជាធ្វើឲ្យគាត់មិនអាចរកត្រីបានដូចពីមុនឡើយ។

ក្រុមរបស់យើងមើលឃើញថា កត្តាទាំងអស់នេះបានកំពុងធ្វើឲ្យប៉ះពាល់ដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដោយមិនត្រឹមតែរងគ្រោះពីកត្តាផ្សេងៗដែលកើតឡើងពីទំនប់វារីអគ្គិសនីទេ ប៉ុន្តែប្រជាជនដែលគ្រាន់តែរកត្រីហូបតាមគ្រួសារត្រូវរងគ្រោះបន្ថែមទៀតនៅពេលដែលគាត់មិនបានដឹងទូលំទូលាយពីរឿងរ៉ាវដែលបានកើតឡើងជុំវិញការរស់នៅរបស់គាត់។ ក្រុមអ្នកស្ម័គ្រចិត្តយើង បានជួបប្រជាជនមួយចំនួនដែលបានលើកឡើងពីបញ្ហាស្រដៀងៗគ្នា។ ដូច្នេះហើយទើបក្រុមអ្នកស្ម័គ្រចិត្តយើង សម្រេចចិត្តពិនិត្យមើលទៅលើបញ្ហាតូចៗមួយចំនួនដែលប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់ប្រជាជនតាមគ្រួសារ និងមិនទាន់មានអ្នកស្រាវជ្រាវណាធ្វើទៅលើប្រធានបទយ៉ាងដូច្នេះទេ។

ក្រៅពីបញ្ហានេសាទត្រី ក្រុមរបស់យើង ក៏ចាប់អារម្មណ៍ទៅលើរឿងរ៉ាវប្រវត្តិសាស្ត្ររបស់តំបន់អូរស្វាយដែលបានបង្កើតឡើងដោយអតីតព្រះមហាក្សត្រសម្តេចព្រះ នរោត្តម សីហនុ និងការចូលកាន់កាប់របស់ខ្មែរក្រហមដែលធ្វើឲ្យតំបន់ទទួលរងការបំផ្លិចបំផ្លាញ

១៥ ការសាកសួរពីមតិយោបល់ប្រជាជនកំពុងរស់នៅក្នុងស្រុកបុរីអូរស្វាយសែនជ័យ ឆ្នាំ២០២៤



អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះសម្ភាសអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកបុរីអូរស្វាយសែនជ័យ។ (រូបថត៖ស្រេង លីដា)

ខ្ទេចខ្ទីស្ទើរគ្មានសល់។ ដោយក្រុមអ្នកស្ម័គ្រចិត្តយើងមើលឃើញថា ប្រជាជនទាំងអស់មានអាយុចាស់ជរា ហើយរឿងរ៉ាវដែលគាត់បានដឹងតាំងពីការបង្កើតតំបន់អូរស្វាយនេះងាយនឹងបាត់បង់ ដូច្នេះសារសំខាន់នៃសាច់រឿងទាំងអស់នោះ បានជំរុញទឹកចិត្តដល់ក្រុមអ្នកស្ម័គ្រចិត្តយើង ឲ្យខិតខំស្វះស្វែងប្រមែប្រមូល និងកត់ត្រាពីប្រវត្តិសាស្ត្រផ្ទាល់មាត់ទាំងអស់នេះឡើងពីប្រជាជនផ្ទាល់នៅក្នុងស្រុកបុរីអូរស្វាយសែនជ័យ។





អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះសម្ភាសអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកបុរីអូរស្វាយសែនជ័យ។ (រូបថត៖ស្រេង លីដា)

# វិធីសាស្ត្រស្រាវជ្រាវ

រយៈពេលនៃការសិក្សាស្រាវជ្រាវមានថេរវេលា និងព្រំដែនកំណត់ដែលអាចធ្វើទៅបាន ក្រុមអ្នកស្ម័គ្រចិត្តយើង បានជ្រើសរើសបទសម្ភាសប្រជាជនដែលយើងទទួលបានព័ត៌មានពេញលេញចំនួន ៧នាក់ និងជាអ្នកដែលបានរស់នៅតំបន់អូរស្វាយ តាំងពីតំបន់នោះបង្កើតឡើងរហូតដល់សព្វថ្ងៃ។ ក្រៅពីបទសម្ភាសប្រជាជនដែលក្រុមអ្នកស្ម័គ្រចិត្តយើងបានជ្រើសរើស យើងក៏បានចងក្រងសាច់រឿងពីប្រជាជនផ្សេងៗទៀតចំនួន ៥នាក់ ដែលក្រុមអ្នកស្ម័គ្រចិត្តយើងបានសរសេរដាក់ចូលនៅក្នុងកិច្ចការស្រាវជ្រាវនេះ ដើម្បីឲ្យមានព័ត៌មានបន្ថែមពីប្រជាជនដែលរស់នៅស្រុកបុរីអូរស្វាយផ្ទាល់។ យើងជ្រើសរើសបទសម្ភាសជាមួយអ្នកនេសាទផ្ទាល់ និងប្រពន្ធរបស់អ្នកនេសាទ ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់អំពីជីវិតរបស់ប្រជាជនក្នុងតំបន់អូរស្វាយតាំងពីមុនរហូតដល់សព្វថ្ងៃនេះ។

នៅក្នុងការសរសេររៀបរាប់សាច់រឿង យើងបានជ្រើសរើសយកការដកស្រង់តាមរចនាបទឈីកាហ្គោ (Chicago Style Citation)[១៦] ដើម្បីចង្អុលបង្ហាញឲ្យបានកាន់តែងាយស្រួលពីទិន្នន័យដែលយើងបានប្រើប្រាស់ ។

## ក. ការប្រមូលទិន្នន័យ

ក្រុមអ្នកស្ម័គ្រចិត្តយើង បានជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ តាមរយៈការសម្ភាសដោយផ្ទាល់ពីប្រជាជនដែលបានឆ្លងកាត់រឿងរ៉ាវទាំងអស់នោះ ឬហៅថា ប្រវត្តិសាស្ត្រផ្ទាល់មាត់។ ប្រវត្តិសាស្ត្រផ្ទាល់មាត់ គឺជាវិធីសាស្ត្រនៃការសម្ភាសប្រកបដោយគុណភាពដែលសង្កត់ធ្ងន់លើទស្សនៈរបស់អ្នកចូលរួម និងអនុញ្ញាតឲ្យអ្នកស្រាវជ្រាវទទួលបានចំណេះដឹងស៊ីជម្រៅ[១៧]។ ក្នុងអំឡុងពេលដំណើរការប្រវត្តិសាស្ត្រផ្ទាល់មាត់ ក្រុមអ្នកស្ម័គ្រចិត្តយើង និងប្រជាជនដែលស្ម័គ្រចិត្តចូលរួមក្នុងការសិក្សាស្រាវជ្រាវ បានបង្កើតទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ថែមទាំងសហការគ្នាដើម្បីទទួលបានព័ត៌មានយ៉ាងទូលំទូលាយកំឡុងពេលប្រមូលទិន្នន័យ។ ក្នុងកិច្ចការសម្ភាសបែបនេះ ក្រុមអ្នកស្ម័គ្រចិត្តយើងហៅថា វិធីសាស្ត្រប្រមូលប្រវត្តិសាស្ត្រផ្ទាល់មាត់ ហើយវិធីសាស្ត្រនេះ បានជួយឲ្យក្រុមរបស់យើងខ្ញុំ ប្រមូលទិន្នន័យបែបពិពណ៌នាបានយ៉ាងក្បោះក្បាយ និងទូលំទូលាយដោយមិនមែនត្រឹមតែសាច់រឿងដែលទាក់ទងទៅនឹងប្រធានបទនោះទេ ប៉ុន្តែយើងទទួលបានព័ត៌មានទាក់ទងនឹងរឿងរ៉ាវសំខាន់ៗជាច្រើន ដែលបានកើតឡើងនៅតំបន់អូរស្វាយ ដែលជាទិន្នន័យសំខាន់សម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយ។ ក្រុមអ្នកស្ម័គ្រចិត្តយើងប្រមូលប្រវត្តិសាស្ត្រផ្ទាល់មាត់យ៉ាងដូច្នេះ គឺរំពឹងថានឹងអាចជួយបំពេញក្នុងកំណត់ត្រាប្រវត្តិសាស្ត្របានច្បាស់លាស់ តាមរយៈការប្រមូលនូវបទពិសោធន៍ផ្ទាល់ពីប្រជាជនដែលផ្តល់បទសម្ភាស និងផ្តល់នូវការយល់ដឹងអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាក់ស្តែង។

---

១៦ Courtney Gahan, « Chicago Style Citation Examples | Website, Book, Article, Video,»Scribbr, Published on July 25, 2018 Revised on April 9, 2024, https://www.scribbr.com/chicago-style/citation-examples/#:~:text=Author%20first%20name%20last%20name,%2C%20page%20number(s).&text=Albert%20Einstein%2C%20The%20Meaning%20of,1923)%2C%20-44%E2%80%9345.

១៧ Patricia Leavy,"Oral History Understanding Qualitative Research," Oxford University Press, 2011, https://global.oup.com/academic/product/oral-history-9780195395099?cc=us&lang=en&.

## ខ. ការវិភាគទិន្នន័យ

ជាដំបូង ក្រុមអ្នកស្ម័គ្រចិត្តរបស់យើង ធ្វើប្រតិចារិកពីបទសម្ភាសប្រជាជនចំនួន ៧នាក់ ដែលយើងបានជ្រើសរើស ដើម្បីផ្តល់ភាពងាយស្រួលដល់យើងធ្វើការជ្រើសរើសយកចំណុចសំខាន់ៗមកវិភាគ។ ដើម្បីបង្កើតអត្ថន័យពីរឿងរ៉ាវរបស់ប្រជាជនដែលយើងបានសម្ភាស យើងនឹងអនុវត្តទម្រង់នៃការវិភាគប្រៀបធៀបថេរ ដែលពាក់ព័ន្ធនឹងការកាត់បន្ថយទិន្នន័យតាមរយៈការសរសេរកូដតាមប្រធានបទថេរ[១៨]។ ក្រុមអ្នកស្ម័គ្រចិត្តរបស់យើងទទួលបានព័ត៌មានច្បាស់លាស់ ដោយសារតែការវាយចម្លងបទសម្ភាសប្រជាជន បន្ទាប់មកយើងចាប់ផ្តើមអានប្រតិចារិកនោះម្តងហើយម្តងទៀត។ ទន្ទឹមនឹងនោះ យើងបានកត់ចំណាំនូវអ្វីដែលទាក់ទាញចំណាប់អារម្មណ៍របស់យើង ឬ ព័ត៌មានដែលសំខាន់នៅក្នុងសាច់រឿងរបស់ប្រជាជន។ បន្ទាប់មកយើងចាប់ផ្តើមសរសេរប្រធានបទធំៗផ្សេងៗគ្នាចេញពីបទសម្ភាសទាំងនោះ ដើម្បីយកធ្វើជាចំណុចគោលងាយស្រួលក្នុងការស្វែងយល់ និងវិភាគទៅលើសាច់រឿងនីមួយៗ ។

## គ. របៀបនៃការសិក្សាស្រាវជ្រាវ

មុនពេលសម្ភាសជាផ្លូវការ យើងបានចំណាយពេលជាច្រើនសប្តាហ៍ដើម្បីធ្វើការស្រាវជ្រាវអំពីសហគមន៍ដែលយើងនឹងចុះទៅសម្ភាស។ យើងក៏បានត្រៀមកម្រងសំណួរជាក់លាក់មួយសម្រាប់សួរទៅកាន់ប្រជាជនដើម្បីងាយស្រួលក្នុងដំណើរការសម្ភាសរបស់យើង។ ដោយមានការអនុញ្ញាត និងគាំទ្រពីអាជ្ញាធរនៅខេត្តស្ទឹងត្រែង ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការធ្វើកិច្ចការងារនេះជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម យើងបានធ្វើដំណើរទៅកាន់ភូមិ និងកោះនានា ដែលស្ថិតនៅស្រុកបុរីអូរស្វាយសែនជ័យដោយផ្ទាល់ ហើយបានជួបជាមួយប្រជាជនជាច្រើនដែលយើងកំពុងតែស្វែងរក។ ក្នុងចំណោមប្រជាជនទាំងអស់នោះ មានសាច់រឿងពិសេសរៀងៗខ្លួន ហើយយើងបានជ្រើសរើសសាច់រឿងរបស់ប្រជាជនចំនួន ៧នាក់។ ប្រជាជនទាំង ៧ នាក់ បានរៀបរាប់យ៉ាងលម្អិតអំពីបទពិសោធន៍ជីវិតរបស់ខ្លួនតាំងពីពេលដែលចាប់ផ្តើមមករស់នៅតំបន់អូរស្វាយ រហូតមកដល់សព្វថ្ងៃ។ ការសម្ភាសបានធ្វើឡើងនៅផ្ទះរបស់គាត់រៀងៗខ្លួន។ មុនពេលសម្ភាស យើងបានចំណាយពេលជាច្រើនម៉ោង ដើម្បីបង្កើតទំនាក់ទំនងជាមួយប្រជាជន ដូចជា ណែនាំខ្លួនរបស់សមាជិកក្រុមអ្នកស្ម័គ្រចិត្ត សួរអំពីសុខទុក្ខរបស់គាត់ យកចិត្តទុកដាក់ចំពោះគាត់ បង្ហាញភាពស្មោះត្រង់ ការគោរព និងរៀបរាប់ពីសារសំខាន់នៃកិច្ចការស្រាវជ្រាវរបស់យើង។ យើងបានសួរអំពីស្ថានភាពសុខភាពរបស់គាត់ និងផ្តល់ព័ត៌មានអំពីកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីផ្តល់ទំនុកចិត្តដល់គាត់។ ការធ្វើដូច្នេះ ពិតជាមានសារសំខាន់សម្រាប់ដំណើរការសម្ភាសរបស់យើងឲ្យទទួលបានព័ត៌មានពិត និងក្បោះក្បាយ។ ទោះជាយ៉ាងណា ក្នុងពេលសម្ភាស យើងបានជួបការលំបាកមួយចំនួនដែរ។ ឧទាហរណ៍ យើងត្រូវរកវិធីជួយសម្រាលទុក្ខរបស់គាត់ពេលដែលគាត់រៀបរាប់ពីស្ថានភាពដ៏លំបាក និងនៅពេលរំឮកពីជីវិតសោកសៅដែលគាត់បានឆ្លងកាត់យ៉ាងអយុត្តិធម៌នៅរឿងរ៉ាវដែលគាត់បានជួបកន្លងមក ។



*អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះសម្ភាសអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកបុរីអូរស្វាយសែនជ័យ។ (រូបថត៖ ស្រេង លីដា)*

---

១៨ Barney G. Glaser, The constant comparative method of qualitative analysis, 1965.

មុននឹងសម្ភាស យើងបានសុំអនុញ្ញាតថតសំឡេង និងថតរូប ដោយពន្យល់ប្រាប់គាត់ថា ការធ្វើដូច្នេះ វាចាំបាច់សម្រាប់កិច្ចការស្រាវជ្រាវរបស់យើង។ យើងបានសួរសំណួរបើកចំហ ដើម្បីឲ្យគាត់មានឱកាសរំឭកបទពិសោធន៍របស់គាត់ដោយសេរី និងនិយាយអ្វីដែលគាត់ចង់និយាយ។ ការសម្ភាសនីមួយៗ ចំណាយពេលជិតមួយម៉ោង ឬច្រើនជាងនេះ ទៅតាមការចងចាំ និងការពេញចិត្តចែករំលែករបស់គាត់។ ដំបូងឡើយ យើងបានស្នើសុំឲ្យគាត់រៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួន ហើយបន្ទាប់មក អនុញ្ញាតឲ្យគាត់និយាយដោយសេរីអំពីប្រវត្តិតំបន់អូរស្វាយដោយមិនមានការរំខាន ឬសួរសំណួរច្រើនឡើយ ។ យើងចាប់ផ្ដើមថា «សូមប្រាប់យើងអំពីអ្វីដែលបានកើតឡើងនៅតំបន់អូរស្វាយនេះដូចជាការបង្កើតតំបន់អូរស្វាយ សង្គ្រាម និងអ្វីផ្សេងទៀតដែលអ៊ំបានដឹង» ។ ជាធម្មតា យើងរក្សាភាពស្ងៀមស្ងាត់ និងយកចិត្តទុកដាក់ស្ដាប់សាច់រឿងរបស់គាត់ លើកលែងតែសួរសំណួរមួយចំនួនដូចជា «ហើយបន្ទាប់មកយ៉ាងម៉េចដែរ?» ឬ «តើមានអ្វីកើតឡើងបន្ទាប់មកទៀត?» និងសំណួរបើកចំហផ្សេងៗ ដើម្បីបន្តការសន្ទនាទៅមុខ។ ជាទូទៅ យើងបានសួរសំណួរបន្ថែមនៅពេលដែលយើងចាប់អារម្មណ៍លើចំណុចជាក់លាក់នៅក្នុងការពិពណ៌នារបស់គាត់ ហើយចុងក្រោយយើងបានសួរអំពីក្ដីបារម្ភរបស់គាត់ចំពោះជីវិតរស់នៅបច្ចុប្បន្ន សំណូមពរ និងបានថ្លែងអំណរគុណដល់គាត់នៅពេលដែលយើងបញ្ចប់ការសម្ភាស។



*អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះមើលការនេសាទត្រីរបស់អ្នកនេសាទនៅកោះឈើទាលតូច។ (រូបថត៖ ស្រេង លីដា)*

# ប្រវត្តិប្រជាជនចូលរួមក្នុងកិច្ចការស្រាវជ្រាវ

### ១. ណាត់ សាយ ភេទប្រុស អាយុ ៦១ឆ្នាំ

ប្រកបរបរធ្វើស្រែចម្ការ និងនេសាទត្រីដើម្បីចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ។ ណាត់ សាយ រស់នៅភូមិកោះញ៉ោតាំងពីកំណើត។ គាត់គឺជាប្រជាជនម្នាក់ដែលដឹងឮរឿងរ៉ាវស្ទើរតែគ្រប់បែបយ៉ាងតាំងពីជំនាន់សម្តេចតាយាងមកបង្កើតតំបន់អូរស្វាយនេះរហូតមកដល់សព្វថ្ងៃ។ មិនតែប៉ុណ្ណោះ គាត់គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានឆ្លងកាត់រឿងរ៉ាវជូរចត់នៅលើកោះញ៉ោជាច្រើន។ ណាត់ សាយ ក៏ជាអ្នកនេសាទតាំងពីសម័យរំដោះរហូតមកដល់បច្ចុប្បន្ន ហើយមានក្តីព្រួយបារម្ភយ៉ាងខ្លាំងចំពោះអនាគតរបស់ប្រជាជនដែលរស់នៅពឹងផ្អែកលើទន្លេមេគង្គ ។

### ២. សែ ហ្វៃង ភេទប្រុស អាយុ ៦២ឆ្នាំ

សព្វថ្ងៃ សែ ហ្វៃង ជាមេភូមិកោះឈើទាលតូច និងរស់នៅភូមិកោះឈើទាលតូចតាំងពីកំណើត។ សែ ហ្វៃង គឺជាកូនអ្នកនេសាទ និងជាអ្នកនេសាទដោយខ្លួនឯងរកត្រីដើម្បីចិញ្ចឹមគ្រួសារ។ នៅក្នុងរបបខ្មែរក្រហម សែ ហ្វៃង រស់នៅលើកោះឈើទាលតូច។ សែ ហ្វៃង ក៏ជាប្រជាជនម្នាក់ក្នុងចំណោមប្រជាជនជាច្រើនបានដឹងពីទិដ្ឋភាពជាក់ស្តែងជុំវិញបញ្ហាប្រឈមដែលកំពុងកើតមាននៅលើកោះឈើទាលតូច។ សែ ហ្វៃង បានស្វែងយល់ និងចូលរួមដោះស្រាយពីទុក្ខធុរៈដែលប្រជាជននៅក្នុងភូមិរបស់គាត់កំពុងតែជួបប្រទះ និងនាំគ្នាកសាងជីវិតថ្មីបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ។ ក្រុមគ្រួសាររបស់គាត់រស់នៅពឹងផ្អែកលើការនេសាទ ដាំថ្នាំជក់ និងធ្វើស្រែជាដើម។ សព្វថ្ងៃនេះ សែ ហ្វៃង កំពុងជួបប្រទះបញ្ហា រួមមាននេសាទមិនបានត្រីដូចពីមុន របបទឹកមិនទៀងទាត់ រុក្ខជាតិ និងត្រីនៅក្នុងទន្លេមេគង្គមានការថយចុះជាខ្លាំង ដែលធ្វើឲ្យប៉ះពាល់ដល់ជីវិតរស់នៅប្រចាំថ្ងៃ។

### ៣. ស្រេង ទិត្យ ភេទប្រុស អាយុ ៥១ឆ្នាំ

សព្វថ្ងៃរស់នៅភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ គាត់បានដឹងពីប្រវត្តិតំបន់អូរស្វាយ និងបានឆ្លងកាត់របបខ្មែរក្រហមនៅទីនោះ។ គាត់រស់នៅពឹងផ្អែកទៅលើមុខរបរនេសាទត្រីជាចម្បង សម្រាប់ចិញ្ចឹមគ្រួសារ។ ប៉ុន្តែមកដល់សព្វថ្ងៃនេះ គាត់កំពុងតែជួបបញ្ហានៅពេលទៅនេសាទត្រីមិនបានដូចពីមុន ហើយគាត់មានការព្រួយបារម្ភណាស់ចំពោះការបាត់បង់ធនធានត្រីបន្តិចម្តងៗដែលធ្វើឲ្យជីវភាពក្រុមគ្រួសាររបស់គាត់កាន់តែពិបាកក្នុងការរស់នៅប្រចាំថ្ងៃ។

### ៤. ភេ ឈុំ ភេទប្រុស អាយុ ៧០ឆ្នាំ

រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ភេ ឈុំ ជាប្រជាជនម្នាក់ក្នុងចំណោមប្រជាជនជាច្រើនដែលសម្តេចព្រះនរោត្តម សីហនុ បានកៀងគរឲ្យមករស់នៅតំបន់អូរស្វាយ តាំងពីឆ្នាំ១៩៦៨។ ភេ ឈុំ បានឃើញពីភាពរីកចម្រើន និងការធ្លាក់ចុះរបស់តំបន់អូរស្វាយ តាំងពីសម័យសង្គមរាស្ត្រនិយម។ មិនតែប៉ុណ្ណោះ ភេ ឈុំ ធ្លាប់ធ្វើជាអ្នកដោះមីន ដឹកជញ្ជូនគ្រាប់ និងជាអតីតកងទ័ពនៅក្នុងរបបខ្មែរ

ក្រហម។ សង្គ្រាម បានបន្សល់ទុកស្នាមរបួសជាប់នឹងខ្លួនរបស់គាត់រហូតមកដល់សព្វថ្ងៃនេះ។

គេ ឈុំ គឺជាប្រជាជនម្នាក់ដែលបានឃើញពីភាពសម្បូរបែបរបស់ត្រី នៅក្នុងទន្លេមេគង្គក្បែរកន្លែងដែលគាត់រស់នៅ ហើយគាត់ក៏ធ្លាប់ជាអ្នកនេសាទពីមុនមកដែរ។ គេ ឈុំ បានបង្ហាញពីក្តីបារម្ភចំពោះអនាគតកូនចៅជំនាន់ក្រោយដែលមិនបានឃើញភាពសម្បូរបែបនៃត្រីដូចជំនាន់របស់គាត់។

## ៥. ខាំផន ស៊ីទុន ភេទប្រុស អាយុ ៦៥ឆ្នាំ

ជាមេភូមិកោះលូ រស់នៅភូមិកោះលូ ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខាំផន ស៊ីទុន បានជម្លៀសខ្លួនទៅនៅប្រទេសឡាវនៅក្នុងរបបខ្មែរក្រហម។ ស៊ីទុន រស់នៅជិតទំនប់វារីគ្គិសនីជាងគេ។ ស៊ីទុន បានរៀបរាប់ថា សព្វថ្ងៃនេះ ក្រុមគ្រួសាររបស់គាត់ និងប្រជាជនផ្សេងទៀតគ្មានដីធ្វើកសិកម្មគ្រប់គ្រាន់ទេ ហើយការនេសាទត្រីក៏មិនបានផលដូចពីមុនដែរ។ ប្រជាជននៅក្នុងភូមិរបស់គាត់ចំណាកស្រុកកាន់តែច្រើនទៅប្រទេសឡាវ ប្រទេសថៃ ភ្នំពេញ និងតំបន់ផ្សេងៗ ដើម្បីស៊ីឈ្នួល។

## ៦. មុិច ស៊ីណា ភេទស្រី អាយុ ៦២ឆ្នាំ

សព្វថ្ងៃរស់នៅភូមិកោះញ៉ៅ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ មុិច ស៊ីណា មានប្រវត្តិដូរចត់តាំងតែពីតូច។ ក្រុមគ្រួសាររបស់ ស៊ីណា រកស៊ីនេសាទត្រីដើម្បីចិញ្ចឹមជីវិត។ នៅក្នុងរបបខ្មែរក្រហម ស៊ីណា ត្រូវខ្មែរក្រហមបង្ខំឲ្យរៀបការចំនួន ៣ដង។ សព្វថ្ងៃនេះ ប្ដីរបស់ ស៊ីណា បានស្លាប់ដោយសារជំងឺ។ គាត់និយាយថា ក្រុមគ្រួសាររបស់គាត់ធ្លាប់តែរកត្រីបានលក់មួយថ្ងៃ ១០០ ទៅ២០០គីឡូក្នុងមួយថ្ងៃ ប៉ុន្តែសព្វថ្ងៃនេះ បែរជាមកទិញត្រីហូបពីឡាវទៅវិញ។ ស៊ីណា មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការរស់នៅក្រោមទំនប់វារីគ្គិសនី។ គាត់ព្រួយបារម្ភណាស់ថា ជីវិតរបស់គាត់មិនដឹងថ្ងៃណាស្លាប់ ដោយសារតែបាក់ទំនប់នោះទេ។

## ៧. ភួយ កំផែង ភេទប្រុស អាយុ ៧៤ឆ្នាំ

សព្វថ្ងៃរស់នៅភូមិកោះញ៉ៅ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ កំផែង បានដឹងរឿងរ៉ាវប្រវត្តិសាស្ត្រយ៉ាងច្រើនតាំងពីការបង្កើតតំបន់អូរស្វាយរហូតមកទល់សព្វថ្ងៃនេះ ព្រោះគាត់បានមករស់នៅតំបន់អូរស្វាយតាំងពីទសវត្សរ៍ ៦០មក។ កំផែង ជាអតីតកងទ័ពខ្មែរក្រហម និងបានរត់គៀសខ្លួនទៅប្រទេសវៀតណាម។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ កំផែង រកស៊ីនេសាទត្រីជាប្រចាំ ហើយមានក្តីព្រួយបារម្ភពីការរស់នៅថ្ងៃអនាគតដោយសារតែត្រីចេះតែហិនហោចទៅជាបន្តបន្ទាប់ ។



*ប្រពន្ធរបស់អ្នកនេសាទរស់នៅលើកោះស្នែង ស្ថិតនៅភូមិកោះស្នែង ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ។*
*(រូបថត៖ ស្រេង លីដា)*

# សាច់រឿងរបស់ប្រជាជន ៧នាក់ ដែលបានជ្រើសរើស

ដោយផ្អែកលើការសរសេរកូដតាមប្រធានបទ យើងបានបង្កើតចំណងជើងគោលសំខាន់ៗចំនួន ៥ ចំណងជើង ដើម្បីស្វែងយល់លើប្រធានបទរបស់យើងឲ្យកាន់តែងាយស្រួល។ ប្រជាជនម្នាក់ៗដែលយើងបានជ្រើសរើសយកមកចូលរួមក្នុងការពិភាក្សានេះ បានជួបប្រទះនឹងចំណុចចំណងជើងគោលទាំងនោះទៅតាមបទពិសោធន៍រៀងៗខ្លួន។ ចំណងជើងគោលទាំង ៥ចំណងជើងនោះ រួមមាន **១. បំលាស់ប្តូរបរិបទសង្គម, ២. អត្តិភាពដ៏អាក្រក់, ៣.ការស្លាប់និងការចាប់កំណើតឡើងវិញ, ៤. ការប្រឈមមុខនឹងបញ្ហាអតីតកាល និងការវិវត្តន៍របស់សង្គម, និង ៥. ការជាប់គាំងក្នុងការស្វែងរកដំណោះស្រាយ។**

## បំលាស់ប្តូរបរិបទសង្គម

«ការផ្លាស់ប្តូរស្ថានភាពសង្គមរបស់អ្នក គឺជាការផ្លាស់ប្តូរជីវិតរបស់អ្នក។ បរិបទសង្គមប៉ះពាល់ដល់របៀបដែលអ្នកប្រព្រឹត្ត គិត និងបកស្រាយ។ វាប៉ះពាល់ដល់ថាតើអ្នកមានអារម្មណ៍ល្អឬមិនល្អ។ វាអាចប៉ះពាល់ដល់ថាតើនៅក្នុងបរិយាកាសជាក់លាក់ណាមួយអ្នកជោគជ័យ ឬ បរាជ័យ»[១៩]។ នៅក្នុងប្រទេសកម្ពុជា ប្រជាជនបានប្រឹងប្រែងសម្របខ្លួនទៅតាមបរិបទសង្គមដែលផ្លាស់ប្តូរមិនចេះឈប់ឈរ ពី«សទៅខ្មៅ» និងពី «ខ្មៅទៅស»។ ស្ថានភាពទាំងអស់នេះ បានផ្លាស់ប្តូរជីវិតរបស់ប្រជាជនទាំងស្រុង។ ប្រជាជនដែលយើងបានជ្រើសរើសយកមកពិភាក្សានៅក្នុងកិច្ចការស្រាវជ្រាវនេះ មានដើមកំណើតមកពីកន្លែងផ្សេងៗគ្នា ប៉ុន្តែក្នុងគោលបំណងតែមួយ គឺការរស់នៅប្រកបដោយសុភមង្គល។ ប្រជាជនខ្លះ កើតនៅតំបន់អូរស្វាយតាំងពីដើម ហើយបន្តរស់នៅក្នុងតំបន់អូរស្វាយ រហូតដល់បច្ចុប្បន្ន។ ចំណែកប្រជាជនមួយចំនួនផ្សេងទៀត បានចាកចេញពីស្រុកកំណើតមករស់នៅតំបន់អូរស្វាយតាមការប្រកាសរបស់សម្តេច នរោត្តម សីហនុ ដោយដឹងថា តំបន់អូរស្វាយ ជាកន្លែងសម្បូរទាំងធនធានធម្មជាតិ និងជាតំបន់អាចឲ្យប្រជាជនងាយប្រកបរបរចិញ្ចឹមជីវិត ។

**ភេ ឈុំ** បានផ្លាស់មករស់នៅតំបន់អូរស្វាយតាមការអំពាវនាវរបស់សម្តេច នរោត្តម សីហនុ បានរៀបរាប់ថា៖

«ខ្ញុំមករស់នៅតំបន់អូរស្វាយនេះ ដំបូងដោយគ្មានទ្រព្យសម្បត្តិអ្វីទាល់តែសោះ ប៉ុន្តែក្រោយមកមានការចែកដី ចែកផ្ទះ សាងសង់មន្ទីរពេទ្យ សាលារៀន ហើយមិនយូរប៉ុន្មានតំបន់អូរស្វាយបានប្រែក្លាយទៅជាសហគមន៍ពេញលេញមួយ។ ខ្ញុំមិនមានការខ្វះខាតអ្វីឡើយពេលមករស់នៅតំបន់អូរស្វាយនៅក្នុងសម័យសង្គមរាស្ត្រនិយម។ ខ្ញុំរស់នៅជាមួយឪពុកម្តាយ ចូលរួមមើលថែរក្សាទឹកដីព្រំដែន និងប្រកបមុខរបរនេសាទដែលមានត្រីសម្បូរបែប។ មិនយូរប៉ុន្មាន លន់ នល់ បានផ្តួលរំលំសម្តេច នរោត្តម សីហនុ ។ ខ្ញុំរស់នៅតំបន់អូរស្វាយដដែល ដោយគ្រាន់តែប្តូរការរស់នៅក្រោមការគ្រប់គ្រងរបបសាធារណរដ្ឋខ្មែរវិញ។ មិនយូរប៉ុន្មានខ្មែរក្រហមបានវាយចូលមក ជីវិតរបស់ខ្ញុំត្រូវផ្លាស់ប្តូរទាំងស្រុង។ ខ្ញុំមិនអាចរស់នៅ និងរកស៊ីបានតាមចិត្តចង់ដូចពីមុននោះទេ។ អ្វីៗត្រូវធ្វើតាមអង្គការ។ ភាពហេវហត់វេទនា និងការប្រឈមមុខនឹងសេចក្តីស្លាប់មានគ្រប់ពេលវេលាទាំងអស់។ រហូតដល់ពេលនេះ ខ្ញុំនៅតែចងចាំពាក្យថា សម្លាប់ៗ

១៩ CO2 Couching, “CHANGE YOUR SOCIAL CONTEXT, CHANGE YOUR LIFE,” CO2 Couching, OCTOBER 24, 2013.

ជាប់មករហូត ព្រោះពេលនោះ ខ្ញុំឮពាក្យថា សម្លាប់នេះមិនដែលដាច់សោះឡើយ»។

ចំណែកឯ **ខាំផន ស៊ីទុន** គឺជាប្រជាជនដែលកើតនៅតំបន់អូរស្វាយ និងមានគ្រួសារជាអ្នកនេសាទត្រីដើម្បីចិញ្ចឹមជីវិត។ ស៊ីទុន ត្រូវបង្ខំចិត្តចាកចេញពីស្រុកកំណើតរបស់គាត់នៅក្នុងឆ្នាំ១៩៧០ ដើម្បីភៀសខ្លួនទៅរស់នៅក្នុងប្រទេសឡាវ បន្ទាប់ពីប្រទេសកម្ពុជាធ្លាក់ចូលក្នុងសង្គ្រាម។ គាត់បានត្រលប់ចូលមករស់នៅក្នុងប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៧៩ ។

«ខ្ញុំកើតនៅលើភូមិកោះលូ ប្រកបមុខរបរនេសាទចិញ្ចឹមជីវិតយ៉ាងសុខសាន្តតាំងពីដើមឡើយមក ប៉ុន្តែនៅឆ្នាំ១៩៧០ នៅពេលដែលសង្គ្រាមចាប់ផ្ដើមឆេះឆួលឡើង បានធ្វើឲ្យខ្ញុំនិងអ្នកភូមិជាង ១០គ្រួសារ ចាកចេញពីកោះទៅរស់នៅក្នុងប្រទេសឡាវ ដើម្បីគេចចេញពីសង្គ្រាម។ ការចាកចេញពីភូមិកំណើតមិនងាយស្រួលប៉ុន្មានទេ ប៉ុន្តែដើម្បីរក្សាជីវិតរស់នៅខ្ញុំត្រូវតែចាកចេញ។ រហូតដល់ឆ្នាំ១៩៧៩ ខ្ញុំបានត្រលប់មកវិញក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលថ្មី។ អ្វីៗនៅក្នុងភូមិប្រែប្រួលទាំងអស់។ នៅភូមិកោះលូទាំងមូល ត្រូវខ្មែរក្រហមកម្ទេចចោលដោយមានការរុះរើផ្ទះសម្បែង ការកាប់ដីរំលាយភ្លឺស្រែ ធ្វើឲ្យអ្នកភូមិមិនអាចកំណត់ទីតាំងព្រំដីរបស់ខ្លួនពីមុនបានឡើយ។ យើងត្រូវចាប់ផ្ដើមសារជាថ្មីម្ដងទៀតពីបាតដៃទទេ ហើយតស៊ូមកដល់សព្វថ្ងៃនេះ ដោយដោះស្រាយបន្តិចម្ដងៗតាមពេលវេលា»។

មិនខុសអ្វីពី **ម៉ុច ស៊ីណា** ឡើយ ដែលជាក្មេងស្រីម្នាក់ត្រូវខ្មែរក្រហមបង្ខំឲ្យរៀបការចំនួន ៣ដង និងមានភាពភ័យខ្លាចយ៉ាងខ្លាំងចំពោះបរិបទគ្រប់គ្រងសង្គមដែលផ្លាស់ប្ដូរមិនចេះឈប់ឈរនេះ ។

«ខ្ញុំកើតនៅក្នុងខេត្តកំពង់ចាម និងមករស់នៅលើកោះញ៉ៅ ក្នុងតំបន់អូរស្វាយ តាមឪពុកម្ដាយរបស់ខ្ញុំ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ស្រុកទេសសម្បូរសប្បាយណាស់។ មិនយូរប៉ុន្មាន ប្រទេសជាតិបែរជាត្រូវធ្លាក់ក្នុងសង្គ្រាមស៊ីវិលក្នុងរបប លន់ នល់ និងរបបខ្មែរក្រហម ហើយខ្ញុំស្ទើរតែមិនអាចសម្របខ្លួនដើម្បីរក្សាជីវិតបានទេ។ នៅសម័យខ្មែរក្រហម ខ្ញុំមានតួនាទីជា កុមារឈានមុខ រស់នៅព្រាត់ប្រាស់គ្រួសារ គ្មានការជួបជុំបងប្អូនរីករាយដូចមុនទាល់តែសោះ។ វ័យរបស់ខ្ញុំ គឺជាវ័យដែលកំពុងពេញលូតលាស់នៅជាកុមារភាពនៅឡើយ ប៉ុន្តែត្រូវផ្លាស់ប្ដូរភ្លាមៗ និងទទួលរងការធ្វើការងារធ្ងន់ធ្ងរដូចមនុស្សពេញវ័យដទៃទៀត។ ខ្មែរក្រហម បានចាប់បង្ខំខ្ញុំឲ្យរៀបការនៅអាយុ ១២ឆ្នាំ ចំនួនពីរដងមិនបានសម្រេចទេ ហើយខ្ញុំក៏យល់ព្រមពេលដែលខ្មែរក្រហមបង្ខំខ្ញុំឲ្យរៀបការជាលើកទី៣ ដើម្បីរក្សាជីវិតរស់។ ការផ្លាស់ប្ដូរការរស់នៅបែបនេះ គឺផ្ទុយស្រឡះ ពីអ្វីដែលខ្ញុំធ្លាប់បានជួបប្រទះមុនពេលខ្មែរក្រហមចូលមក។

## អត្ថិភាពដ៏អាក្រក់

ប្រជាជនទាំង៧នាក់ បានជួបបទពិសោធន៍ស្រដៀងគ្នាពីមួយជំនាន់ទៅមួយជំនាន់។ នៅក្នុងរបបសង្គមរាស្ត្រនិយម ប្រជាជនម្នាក់ៗ បានជួបភាពរីករាយ សម្បូរសប្បាយ និងពេញចិត្តចំពោះការកសាងសហគមន៍របស់ខ្លួន ដោយមានការជួយជ្រោមជ្រែងពីសម្ដេចព្រះនរោត្តម សីហនុ ផ្ទាល់ក្នុងការអភិវឌ្ឍសហគមន៍។ ក្រោយមកបន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារ សង្គ្រាមបានចាប់ផ្ដើមចូលមកដល់បន្តិចម្ដងៗ ហើយនៅក្នុងភូមិមិនសូវមានសភាពស្ងប់ស្ងាត់នោះទេ។ នៅក្នុងភូមិចេះតែមានការទម្លាក់គ្រាប់បែក មានទាហានចូលមកក្នុងភូមិ។ មិនយូរប៉ុន្មាន របបខ្មែរក្រហមក៏បានកើតឡើង។ គ្មាននរណាម្នាក់លើកឡើងពីភាពរីករាយបន្តទៅទៀតទេ។ នៅក្នុងរបបខ្មែរក្រហម មនុស្សម្នាក់ៗ ហ៊ានធ្វើគ្រប់យ៉ាងដើម្បីរស់ សូម្បីតែលួច និយាយកុហក ដួនពេលខ្លះសម្លាប់អ្នកដទៃដើម្បីរក្សាជីវិតខ្លួនឯង។ នៅក្នុងតំបន់អូរស្វាយ ប្រជាជនអត់ឃ្លានហើយមិនអាចសូម្បីតែចាប់ត្រីដែលសម្បូរបែបពីក្នុងទន្លេយកមកហូបតាមគ្រួសារ ។

**សៃ ហ្វេង** បានរៀបរាប់ពីការលំបាក និងអំពើឃោរឃៅមួយចំនួនដែលគាត់ និងក្រុមគ្រួសារបានជួបប្រទះ នៅក្នុងសម័យខ្មែរក្រហមថា៖

> « ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសចេញពីកោះ ដែលជាកន្លែងកំណើតរបស់ខ្ញុំចល័តទៅកាន់ទីកន្លែងជាច្រើនដែលខ្ញុំមិនធ្លាប់ស្គាល់។ ពេលនោះ ខ្ញុំនៅជាកុមារ ប៉ុន្តែខ្ញុំត្រូវធ្វើការងារដូចមនុស្សពេញវ័យដែលខ្ញុំមិនធ្លាប់ធ្វើពីមុន។ ខ្ញុំមិនមានពេលសម្រាកគ្រប់គ្រាន់ និងទទួលបានអាហារបន្តិចបន្តួចតែប៉ុណ្ណោះ។ សមាជិកគ្រួសាររបស់ខ្ញុំត្រូវខ្មែរក្រហមសម្លាប់ទាំងគ្មានកំហុស ហើយខ្ញុំវិញ ត្រូវរស់នៅឆ្ងាយពីគ្រួសារ និងសាច់ញាតិ ដោយប្រឹងប្រែងដោះស្រាយបញ្ហាតែម្នាក់ឯង »។

បទពិសោធន៍ទាំងនេះ បានឆ្លុះបញ្ចាំងពីការពិត និងការតស៊ូដ៏លំបាករបស់ **សៃ ហ្វេង** ក្នុងវ័យកុមាររបស់គាត់។ ចំណែក **ស្រេង ទិត្យ** ក៏បានឆ្លងកាត់រឿងរ៉ាវខ្មោងងឹតជាច្រើននៅក្នុងរបបខ្មែរក្រហមដែរ ។

> « ខ្ញុំនិងក្រុមគ្រួសារ ត្រូវខ្មែរក្រហមជម្លៀសទៅភូមិផ្សេងដូចប្រជាជនដទៃទៀត ដែលមិនត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុងផ្ទះរបស់ខ្លួននោះទេ។ ពេលនោះ ខ្ញុំស្គមណាស់ គ្មានកម្លាំង ព្រោះខ្ញុំគ្មានអ្វីហូបឡើយ។ ខ្ញុំហូបតែគល់ចេក គល់ល្ហុង គ្មានជីវជាតិដើម្បីទ្រទ្រង់រាងកាយដែលធ្វើការធ្ងន់ៗទាល់តែសោះ។ ជួនកាលឃ្លានពេក ខ្ញុំបានទៅដណ្ដើមបាយជ្រូកមកហូបក៏មានដែរ។ ក្រៅពីការអត់ឃ្លាន និងធ្វើការងារធ្ងន់ ខ្ញុំនិងក្រុមគ្រួសារតែងតែរត់គេចខ្លួនដោយខ្លាចខ្មែរក្រហមចាប់ដាក់ទោស។ ការរត់គេចពីសេចក្តីស្លាប់នេះ ធ្វើឲ្យខ្ញុំនៅតែជិតដាមក្នុងចិត្តជាប់រហូតមក » ។

នៅក្នុងវ័យ ១៥ឆ្នាំ ជាវ័យកំពុងតែពេញទទួលបាននៅការអប់រំ ប៉ុន្តែ **ណាត់ សាយ** វិញ កំពុងតែទទួលរងនូវសេចក្តីភ័យខ្លាចពីការគំរាមកំហែងដល់អាយុជីវិតក្នុងរបបខ្មែរក្រហម។ ណាត់ សាយ រៀបរាប់ថា៖

> « ផ្លូវជីវិតដ៏អាក្រក់បំផុត គឺជីវិតនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំឈឺចាប់ខ្លាំង ពេលព្រាត់ប្រាស់ពីក្រុមគ្រួសារ និងសាច់ញាតិ។ ខ្ញុំឃើញមនុស្សស្លាប់ និងរបួសជារៀងរាល់ថ្ងៃ។ សេចក្តីស្លាប់អាចកើតមានឡើងរាល់វិនាទីមិនថាយប់ថ្ងៃ។ ខ្ញុំជាគ្រូពេទ្យ ត្រូវដើរតាមកងទ័ពខ្មែរក្រហមគ្រប់ពេលវេលា ដើម្បីព្យាបាល និងជួយសង្គ្រោះអ្នករបួស។ ខ្ញុំប្រឈមមុខនឹងសេចក្តីស្លាប់គ្រប់បែបយ៉ាង » ។

## ការស្លាប់ និងការចាប់កំណើតឡើងវិញ

ប្រជាជនជាង ២លាននាក់ បានស្លាប់នៅក្នុងរបបខ្មែរក្រហម ហើយប្រជាជនជាង ៥លាននាក់ រស់រានមានជីវិត ហើយហាក់បីដូចជាបានចាប់កំណើតសារជាថ្មីនៅលើទឹកដីចាស់ដែលគ្មានសេសសល់អ្វីទាំងអស់។ របបខ្មែរក្រហម បានបន្សល់ទុកជនពិការជាង ១៤ម៉ឺននាក់, កុមារកំព្រាប្រមាណ ២០ម៉ឺននាក់ និងស្ត្រីមេម៉ាយជាច្រើន ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម[២០] និងបានខិតខំរើសយកបំណែកសង្គមខ្ទេចខ្ទីមកផ្គុំគ្នាឡើងវិញ។ មនុស្សម្នាក់ៗខិតខំស្វែងរកក្រុមគ្រួសារ និងមនុស្សជាទីស្រលាញ់របស់ខ្លួនដែលបានបែកបាក់ ហើយនាំគ្នាធ្វើដំណើរត្រលប់មកស្រុកកំណើត ដើម្បីកសាងស្រុកភូមិ និងបន្តជីវិតរបស់ខ្លួនវិញ ។

**សៃ ហ្វេង** បានប្រឈមមុខតស៊ូនឹងបញ្ហាប្រឈមជាច្រើនបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ។

> « ខ្ញុំត្រូវកសាងជីវិតឡើងវិញដូចកើតម្តងទៀត។ ខ្ញុំត្រូវខិតខំប្រឹងប្រែងធ្វើគ្រប់យ៉ាង ដើម្បីស្វែងរកអាហារឲ្យបានគ្រប់គ្រាន់ចិញ្ចឹមគ្រួសាររបស់ខ្ញុំ។ ក្រោយមក ខ្ញុំបានចូលធ្វើកងទ័ព ដើរតាមកងទ័ពវៀតណាម ប្រហែល៥ឆ្នាំ ទើបខ្ញុំត្រលប់មកផ្ទះជួបជុំក្រុមគ្រួសារវិញ។ ទោះបីជាមានការលំបាកយ៉ាងណាក៏ដោយ ខ្ញុំនៅតែអាចមានអាហារហូប និង

---

២០ ឧក្រិដ្ឋកម្មបនវាតទីអនុត្តរភាពនិយមចិនប៉េកាំង និងបរវារ ប៉ុលពត អៀង សារី ខៀវ សំផន ក្នុងកំឡុងឆ្នាំ១៩៧៥-១៩៧៨ , ភ្នំពេញ, ១៩៨៣

កសាងជីវិតឡើងវិញងាយស្រួលជាងរស់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំអាចរកត្រីចិញ្ចឹមជីវិតនៅក្នុងទឹកទន្លេមេគង្គក្បែរផ្ទះរបស់ខ្ញុំ និង ធ្វើស្រែចម្ការនៅលើកោះឈើទាលតូចរហូតមក »។

**ភួយ កំផែង** បាននិយាយពីការតស៊ូរស់នៅរបស់គាត់ក្រោយរបបខ្មែរក្រហមដួលរលំថា៖

« ពេលខ្មែរក្រហមដួលរលំភ្លាម ខ្ញុំបានវិលត្រលប់មករស់នៅក្នុងភូមិរបស់ខ្ញុំវិញ។ ការចាប់ផ្តើមរស់នៅដំបូងមិនងាយស្រួលទេ។ ខ្ញុំមិនចង់មានបានអ្វីទេ ខ្ញុំប្រាថ្នាត្រឹមតែស្វះស្វែងរកអាហារហូបឲ្យបានឆ្អែតក្រពះមួយពេលៗ កុំឲ្យអត់ឃ្លានដូចនៅក្នុងរបបខ្មែរក្រហមទៀត។ ក្រៅពីការស្វែងរកអាហារ ខ្ញុំនៅវិលវល់រង់ចាំដំណឹងរបស់ម្តាយឪពុក និងបងប្អូនរបស់ខ្ញុំ ដោយមិនឃើញគាត់ត្រលប់មកផ្ទះវិញសោះ។ ក្រោយមក ខ្ញុំបានទទួលដំណឹងច្បាស់ថា ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ បានស្លាប់ទាំងអស់នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែខ្ញុំនៅតែមិនដឹងថា ខ្មែរក្រហមសម្លាប់គាត់នៅកន្លែងណាទេ។ ខ្ញុំបានចាប់ផ្តើមសាងជីវិតថ្មី និងបានរៀបការ ដោយប្រកបរបរនេសាទត្រី ដាំបន្លែ និងធ្វើស្រែបន្តិចបន្តួចដើម្បីចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ »។

ក្រោយពេលរបបខ្មែរក្រហមដួលរលំ **ម៉ិច ស៊ីណា** បានបង្ហាញចំណាប់អារម្មណ៍ពីការកសាងជីវិតរបស់គាត់ថា៖

« ខ្ញុំហាក់បីដូចមានជីវិតចាប់កំណើតសារជាថ្មីម្តងទៀត។ ខ្ញុំបានវិលត្រលប់មកជួបជុំគ្រួសាររបស់ខ្ញុំឡើងវិញ ដោយចាប់រកស៊ីចិញ្ចឹមជីវិតតាមគ្រួសារដូចកាលពីមុនម្តងទៀត។ ខ្ញុំបានប្រកបមុខរបរធ្វើស្រែចម្ការ និងនេសាទត្រីដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ពេលនោះ ខ្ញុំសំណាងណាស់ ព្រោះខ្ញុំរស់នៅជាប់នឹងទន្លេមេគង្គមិនខ្វះត្រីហូបនោះទេ ថែមទាំងងាយស្រួលក្នុងការនេសាទទៀត »។

១០ឆ្នាំបន្ទាប់ពីបានចាកចោលភូមិកំណើត **ខាំ ផន ស៊ីទុន** និងអ្នកភូមិទាំងអស់ ដែលរត់ទៅប្រទេសឡាវដើម្បីគេចចេញពីរបបខ្មែរក្រហមនោះ បាននាំគ្នាវិលត្រលប់ចូលមកក្នុងភូមិកោះលូ ដែលជាទឹកដីកំណើតវិញ។

« ខ្ញុំមកដល់ភូមិកំណើតវិញពេលនោះ អ្វីៗគឺត្រូវចាប់ផ្តើមសារជាថ្មីឡើងវិញទាំងអស់។ ភូមិកោះលូទាំងមូល ត្រូវបានកម្ទេចចោលទាំងស្រុង រួមមានការរុះរើផ្ទះសម្បែង ការកាប់ដីរំលាយភ្លឺស្រែ ធ្វើឲ្យអ្នកភូមិដែលវិលមកវិញមិនអាចកំណត់ទីតាំងទំហំដីរបស់ខ្លួនពីមុនបាន។ ផ្ទះសម្បែង ត្រូវខ្មែរក្រហមរុះរើសម្រាប់ធ្វើរោងគោ ឬរោងក្របីអស់ជាដើម។ ពេលត្រលប់មកវិញ ខ្ញុំធ្វើជាមេភូមិកោះលូ។ ខ្ញុំមើលឃើញប្រជាជនមានការលំបាកខ្លាំងណាស់ ដោយសារនៅភូមិកោះលូមានផ្ទៃដីតូច ហើយគ្រួសារនីមួយៗ មានដីតិចតួច ដើម្បីធ្វើស្រែចម្ការចិញ្ចឹមជីវិតតែប៉ុណ្ណោះ។ ក្រៅពីការធ្វើស្រែចម្ការ យើងរស់នៅរកត្រីហូបគ្រាន់បានចិញ្ចឹមជីវិតប្រចាំថ្ងៃ »។

## ការប្រឈមមុខនឹងបញ្ហាអតីតកាល និងការវិវឌ្ឍរបស់សង្គម

សង្គមមួយដែលប្រេះស្រាំប្រៀបដូចជាបំណែកកែវមួយដែលបានបែកហើយបិតផ្គុំគ្នាចេញជារូបរាងឡើងវិញ ប៉ុន្តែកែវនោះនៅតែមានស្នាមតភ្ជាប់គ្នាជាប់មករហូតដោយមិនអាចលុបបាន។ ភាពសំខាន់ចំពោះកែវ មិនមែននៅត្រង់ថា តើកែវនោះ មានស្នាមប្រេះឬយ៉ាងណានោះទេ? ផ្ទុយទៅវិញ ថាតើយើងអាចថែរក្សាកែវនោះតាមវិធីណា និងខិតខំប្រែក្លាយកែវចេញពីស្នាមប្រេះដែលអាក្រក់ឲ្យទៅជាស្នាមប្រេះដែលស្រស់ស្អាតបានយ៉ាងដូចម្តេច?

សង្គមកម្ពុជា មិនខុសអ្វីពីកែវប្រេះស្រាំនោះឡើយ។ សង្គ្រាម បានធ្វើឲ្យប្រទេសកម្ពុជា ប្រេះស្រាំ ជិតដាមអតីតកាលដ៏ខ្មៅងងឹត ដែលគ្មាននរណាម្នាក់ប្រាថ្នាចង់ជួបប្រទះម្តងទៀតទេ។ កន្លងមកអស់រយៈពេលជាច្រើនឆ្នាំ ប្រជាជននៅតែជិតដាមនឹងបញ្ហាអតីតកាលរបស់ខ្លួនដែលមិនអាចបំភ្លេចបាន ហើយអតីតកាលទាំងនោះ នៅតែបន្តជះឥទ្ធិពលដល់អ្នករស់រានមានជីវិត

ពីរបបខ្មែរក្រហមរហូតដល់សព្វថ្ងៃនេះ។ បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនទៀតដែលបានជះឥទ្ធិពលដល់ប្រជាជនសព្វថ្ងៃនោះ គឺបញ្ហាសុខភាពរបស់ប្រជាជន។ ជាទូទៅ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តែងពើបប្រទះនូវជំងឺ ៥ប្រភេទ រួមមាន ១) ជំងឺលើសឈាម ២) ជំងឺបេះដូង ៣) ជំងឺទឹកនោមផ្អែម ៤) ជំងឺស្ទះផ្លូវដង្ហើមរ៉ាំរ៉ៃ និងជំងឺរបេងសួត និង៥) ជំងឺមហារីកសុដន់[២១]។

ទន្ទឹមនឹងនេះ ការវិវឌ្ឍរបស់សង្គម បានជួយដល់អ្នករស់រានមានជីវិតជាច្រើនឲ្យមានឱកាសរៀនសូត្រពីបទពិសោធន៍របស់ខ្លួន ការចូលរួមថែរក្សាប្រវត្តិសាស្ត្រដ៏ជូរចត់ និងការការពារអំពើប្រល័យពូជសាសន៍មិនឲ្យកើតឡើងវិញបានដែរ។ ទោះបីជាយ៉ាងនេះក្តី ប្រជាជនក៏ត្រូវប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមថ្មីៗទៅតាមការវិវឌ្ឍរបស់សង្គមមួយនេះដែរ ។

**សែ ហ៊្វេង** បានប្រឈមមុខនឹងបញ្ហាជាច្រើននៅលើកោះឈើទាលតូចដែលគាត់រស់នៅសព្វថ្ងៃ។សែហ៊្វេងបានលើកឡើងពីបញ្ហាមួយចំនួន ដែលគាត់ជួបប្រទះថា៖

« សព្វថ្ងៃនេះ ខ្ញុំមានអាយុ ៦២ឆ្នាំ ហើយសុខភាពរបស់ខ្ញុំក៏ទ្រុឌទ្រោមដែរ។ ខ្ញុំធ្លាប់ធ្វើការធ្ងន់នៅក្នុងរបបខ្មែរក្រហម ដូច្នេះសុខភាពរបស់ខ្ញុំក៏ទ្រុឌទ្រោមទៅតាមនោះ។ ក្រៅពីនេះ ការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ខ្ញុំមិនសូវល្អទេ។ ខ្ញុំមិនសូវមានដីគ្រប់គ្រាន់ដើម្បីធ្វើស្រែចម្ការ។ ចំណែកឯរបរនេសាទវិញមិនទទួលបានទិន្នផលត្រីដូចកាលពីមុននោះទេ ព្រោះដោយសារតែការអភិវឌ្ឍទំនប់វារីអគ្គីសនី និងកត្តារំខានផ្សេងៗ។ខ្ញុំបានដាំថ្នាំជក់លក់ដើម្បីផ្គត់ផ្គង់គ្រួសារ ប៉ុន្តែតម្រូវការទីផ្សារមិនសូវល្អប៉ុន្មានឡើយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រជាជនផ្សេងក៏មិនខុសពីខ្ញុំប៉ុន្មានដែរ ពួកគេត្រូវបង្ខំចិត្តចំណាកស្រុកទៅធ្វើការនៅប្រទេសថៃម៉ាឡេស៊ី និងតំបន់ផ្សេងៗ ដើម្បីស្វែងរកឱកាសការងារ » ។

ចំណែក **ភួយ កំផែង** បានចែករំលែកពីបទពិសោធន៍របស់គាត់ថា៖

« អតីតកាលនៅតែជិតជាមក្នុងជីវិតរបស់ខ្ញុំ។ សព្វថ្ងៃនេះ ពេលខ្ញុំនឹកឃើញការស្លាប់របស់ក្រុមគ្រួសាររបស់ខ្ញុំយ៉ាងអយុត្តិធម៌ម្តងៗ ទឹកភ្នែករបស់ខ្ញុំនៅតែស្រក់ចុះមក។ ទោះបីជារឿងរ៉ាវឈឺចាប់ទាំងអស់នោះនៅតែតាមលងបន្លាចខ្ញុំ ប៉ុន្តែខ្ញុំមានសំណាងដែលមានឱកាសរស់នៅក្នុងសង្គមថ្មីដែលគ្មានសង្គ្រាមដូចសព្វថ្ងៃនេះ។ នៅតាមផ្លូវធ្វើដំណើរសម្រាប់ជីវិតយើងសព្វថ្ងៃ មិនមែនគ្មានបញ្ហាអ្វីនោះទេ ប៉ុន្តែវាប្រសើរជាងរស់នៅក្នុងរបបខ្មែរក្រហម។ សព្វថ្ងៃនេះខ្ញុំមើលឃើញថា ប្រជាជននៅតំបន់អូរស្វាយ កំពុងតែជួបបញ្ហាប្រឈមមុខដោយសារការថយចុះចំណូលប្រចាំថ្ងៃពីការនេសាទត្រីមិនបាន ហើយប្រជាជនត្រូវចាកចេញពីផ្ទះទៅរស់នៅតំបន់ផ្សេងឬទៅបរទេសដើម្បីរកចំណូលមកផ្គត់ផ្គង់គ្រួសារបន្ថែម »។

**ខាំផន ស៊ីទុន** គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលប្រឈមមុខនឹងបញ្ហាអតីតកាល និងផលលំបាកទាក់ទងនឹងការបាត់បង់ធនធានធម្មជាតិនៅក្នុងសហគមន៍របស់គាត់សព្វថ្ងៃនេះ។

« ខ្ញុំសង្កេតឃើញថា ប្រជាជនដែលរស់នៅលើកោះដូចខ្ញុំ ប្រឈមមុខនឹងបញ្ហាច្រើនណាស់។ យើងមិនមានឱកាសក្នុងការរកស៊ីឲ្យបានទូលំទូលាយដូចប្រជាជននៅលើដីគោកនោះទេ។ បញ្ហាខុសប្រក្រតីនៃធម្មជាតិ ប៉ះពាល់ដល់សុវត្ថិភាពនៃការរស់នៅរបស់យើង ដូចជា លំហូរទឹកមិនទៀងទាត់ និងការភ័យខ្លាចចេញពីគ្រោះថ្នាក់នៃការបាក់ទំនប់វារីអគ្គីសនី។ មិនតែប៉ុណ្ណោះ សព្វថ្ងៃនេះ ខ្ញុំមើលឃើញថាផ្ទៃដីកោះមានការបាក់ស្រុតម្តងបន្តិចៗដែលអាចបង្កជាហានិភ័យថ្ងៃអនាគតដែរ »។

---

២១ “ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម,” មជ្ឈមណ្ឌលឯកសារកម្ពុជា, accessed May 31, 2024, https://www.dccam.org/homepage /health /rights-and-welfare-of-khmer-rouge-survivor//

## ការជាប់គាំងក្នុងការស្វែងរកដំណោះស្រាយ

៤៥ឆ្នាំកន្លងមកនេះ ប្រជាជនកម្ពុជារស់នៅដោយស្ងប់ស្ងាត់ជាងមុនៗ និងសន្តិភាព ក្រោយពីរបបខ្មែរក្រហមបានដួលរលំ។ ប្រជាជនម្នាក់ៗមានសិទ្ធិសេរីភាពក្នុងការរស់រានមានជីវិត ការហូបចុក ការនិយាយស្តី និងទទួលបានការអប់រំទៅតាមស្តង់ដាមួយរបស់ប្រទេសដែលគ្មានសង្គ្រាម។ ទោះបីជាយ៉ាងនេះក្តី ប្រជាជននៅតែមានផលរំខានពីបញ្ហាអតីតកាលក៏ដូចជាបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍដូចប្រជាជនដែលរស់នៅតំបន់អូរស្វាយជាដើម ។

ការអភិវឌ្ឍទំនប់វារីអគ្គិសនីផ្តល់ផលប៉ះពាល់ដល់ជីវិតរបស់មនុស្សជាច្រើនដែលរស់នៅអាស្រ័យផលពីទន្លេមេគង្គ រួមទាំង ប្រជាជននៅស្រុកបុរីអូរស្វាយសែនជ័យ។ ការរីកដុះដាលនៃទំនប់វារីអគ្គិសនី ធ្វើឲ្យប្រជាជនពិបាកក្នុងការស្វែងរកត្រី ដើម្បីហូបជាអាហារប្រចាំថ្ងៃ។ ទោះបីជាការសិក្សាស្រាវជ្រាវផ្សេងៗ បានបង្ហាញពីផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជន និងធម្មជាតិពីការសាងសង់ទំនប់វារីអគ្គិសនីនេះក៏ដោយ ប៉ុន្តែអ្វីៗហាក់បីដូចជាមិនទាន់មានដំណោះស្រាយឲ្យមានប្រសិទ្ធភាពនោះទេ ព្រោះទំនប់វារីអគ្គិសនីបានសាងសង់រួចទៅហើយ។ ប្រជាជនបានត្រឹមតែត្អូញត្អែរថារកត្រីមិនបានដូចពីមុន ដើម្បីហូបប្រចាំថ្ងៃ លំហូរទឹកឡើងចុះមិនទៀងទាត់ ធ្វើឲ្យពិបាកក្នុងការធ្វើដំណើរ និង ដើមឈើបន្តងាប់បន្តិចម្តងៗ ហើយបញ្ហានេះ នៅតែមិនទាន់មានដំណោះស្រាយណាមួយឲ្យមានលទ្ធផលនៅឡើយទេ។ ក្រៅពីនោះ ប្រជាជនបានលើកឡើងពីភាពស្មុគស្មាញ ថាការអនុវត្តច្បាប់លើការចាប់ត្រីដោយប្រើឧបករណ៍ខុសច្បាប់ទ្រង់ទ្រាយធំមិនសូវមានប្រសិទ្ធភាព ខណៈពេលដែលច្បាប់កាន់តែរឹតបន្តឹង និងធ្វើឲ្យពិបាកដល់ប្រជាជនធម្មតាដែលរកត្រីគ្រាន់តែបរិភោគប្រចាំថ្ងៃទៅវិញ ។

**សែ ហ្វៃង** បានលើកឡើងពីបញ្ហាដែលមិនទាន់បានដោះស្រាយឲ្យមានប្រសិទ្ធភាពនៅក្នុងសហគមន៍របស់គាត់ថា ៖

« ការធ្វើដំណើរតាមផ្លូវទឹក គឺមានការលំបាកខ្លាំងណាស់នៅរដូវប្រាំងសម្រាប់ប្រជាជនដែលត្រូវមករកស៊ីនៅលើគោក, សិស្សមកសាលារៀន និងការធ្វើដំណើរមកមន្ទីរពេទ្យជាដើម។ ក្នុងទន្លេមានថ្មជាច្រើនផុសឡើងលើផ្ទៃទឹក ចំណែកឯទឹកទន្លេកាន់តែរាក់ទៅៗ ដោយសារការទប់ទឹកដើម្បីផ្គត់ផ្គង់ដល់វារីអគ្គិសនី ដែលធ្វើឲ្យយើងពិបាកក្នុងការបើកទូកឆ្លងទឹក។ ក្រៅពីនេះ ខ្ញុំនៅឃើញមានការនេសាទខុសច្បាប់នៅតែបន្ត ព្រោះប្រជាជនខ្លះមិនទាន់មានការយល់ដឹងពីការប្រព្រឹត្តបទល្មើស និងផលប៉ះពាល់នៃការចាប់ត្រីខុសច្បាប់នេះ។ ជារឿយៗ មន្ត្រីសមត្ថកិច្ចបានការពារ និងចូលរួមចុះអនុវត្តការងាររបស់ខ្លួនជាប្រចាំដែរ ប៉ុន្តែនៅតែមិនអាចគ្រប់គ្រង និងចាត់វិធានការឲ្យមានប្រសិទ្ធភាបានទេ។ ចំណែកឯព្រៃលិចទឹក នៅតែងាប់ ដែលបណ្តាលមកពីទំនប់វារីអគ្គិសនីធ្វើឲ្យទឹកទន្លេមេគង្គឡើងស្រកៗមិនទៀងទាត់ មិនអាចឲ្យដើមឈើលូតលាស់បានទៅតាមធម្មជាតិរបស់វា »។

ចំណែក **ភួយ កំផែង** ក៏យល់ឃើញថា បញ្ហានៃការអនុវត្តច្បាប់ទៅលើជនល្មើសចាប់ត្រីមិនទាន់មានប្រសិទ្ធភាពទេ ហើយការអនុវត្តច្បាប់នោះ ធ្វើឲ្យប៉ះពាល់ដល់ប្រជាជនស្លូតត្រង់ដែលគ្រាន់តែរកត្រីហូបប្រចាំថ្ងៃដែរ ។

« ចំពោះការចាប់ជនល្មើសឆក់ត្រី នៅអនុវត្តមិនទាន់បានល្អទេ ដោយសារខ្ញុំមើលឃើញថា អ្នកចាប់ត្រីខុសច្បាប់នៅតែរួចខ្លួន ហើយការរឹតបន្តឹងច្បាប់ធ្វើឲ្យប្រជាជនមួយចំនួនពិបាករកត្រីហូបណាស់។ ឧទាហរណ៍៖ ចាប់ពីខែ៥ ដល់ខែ១០ មានការបិទការនេសាទ ដោយសារតែរដូវត្រីពង ដូច្នេះយើងមិនអាចរកត្រីហូបបានទេ។ យើងអាចទៅរកត្រីបាននៅកន្លែងណាដែលគេអនុញ្ញាត ហើយកន្លែងដែលគេអនុញ្ញាតនោះ មិនសូវមានត្រីទេ។ ដូច្នេះ ប្រជាជននឹងរកត្រីមិនបានហូបទេក្នុងរយៈពេលនេះ។ លើសពីនេះ ទោះបីខ្ញុំជាអ្នកទន្លេ ជួនពេលខ្លះ ខ្ញុំក៏ភ័យខ្លាចក្នុងការឆ្លងទឹកដែរ។ ពេលខ្លះទឹកឡើង ពេលខ្លះទឹកស្រក ស្រេចលើតែការបិទ និងបើកទំនប់វារីអគ្គីសនី »។

**ខាំផន ស៊ីទុន** ក៏មើលមិនឃើញពីអនាគតនៃការដោះស្រាយបញ្ហាក្នុងសហគមន៍របស់គាត់ដែរ ។

« ប្រជាជនមួយចំនួន រកស៊ីនេសាទមិនស្របច្បាប់ ហើយការប្រើឧបករណ៍អគ្គិសនីខុសច្បាប់នៅតែបន្តមានមិនអស់ឡើយ។ ចំណែកច្បាប់ គឺអនុវត្តតែលើអ្នកនេសាទតូចតាច ដោយរកត្រីគ្រាន់តែហូបប្រចាំថ្ងៃ ដូចជា ដាក់មង ឬសំណាញ់ខុសទីតាំងជាដើម ដោយលើកឡើងថា ការដាក់មង ឬសំណាញ់នៅកន្លែងហាមឃាត់បែបនេះ ជាមូលហេតុធ្វើឲ្យត្រីហិនហោច។ លើសពីនេះ ការងាប់ព្រៃលិចទឹកដែលគ្មានដំណោះស្រាយនៅតែបន្ត ព្រោះព្រៃលិចទឹកទាំងអស់នោះស្ថិតនៅក្រោមទំនប់វារីអគ្គិសនីដែលជាប្រភពចម្បងបង្កឲ្យមានលំហូរទឹកមិនទៀងទាត់ ជួនទឹកលិចខ្លាំង ជួនទឹកស្រកខ្លាំង ធ្វើឲ្យដើមឈើជាជម្រកត្រីងាប់ និងត្រីក៏ហិនហោចទៅតាមនោះដែរ » ។



*ប្រជាជនទៅដាក់មងចាប់ត្រីក្នុងទន្លេមេគង្គ នៅស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (រូបថត៖ ស្រេង លីដា)*



# រឿងរ៉ាវរបស់ប្រជាជនផ្សេងៗ ទៀត ដែលបានចូលរួមក្នុងកិច្ចការស្រាវជ្រាវ

*ប្តីប្រពន្ធអ្នកនេសាទកំពុងដាក់មងក្នុងទន្លេមេគង្គ។ (រូបថត៖ ស្រេង លីដា)*

## ត្រីធ្លាប់មានច្រើនកុះករក្នុងតំបន់អូរស្វាយ

### អត្ថបទដោយ ៖ ស្រេង លីដា

ខ្ញុំឈ្មោះ **ភេ ឈុំ** អាយុ ៧០ឆ្នាំ ភេទប្រុស មានបងប្អូនចំនួន ៥នាក់។ ខ្ញុំបានមករស់នៅតំបន់អូរស្វាយនៅក្នុងឆ្នាំ១៩៦៨ ហើយបានរៀបការនៅក្នុងឆ្នាំ១៩៨០ និងមានកូនចំនួន ៥នាក់ ស្រីចំនួន ២នាក់។

តំបន់អូរស្វាយ ត្រូវបានកសាងឡើងដោយសម្តេចនរោត្តម សីហនុ ដើម្បីការពារទឹកដីពីការឈ្លានពានរបស់ប្រទេសជិតខាង។ ពេលសម្តេច នរោត្តម សីហនុ យាងមក ទ្រង់បានបង្កើតសហគមន៍មួយ និងលើកទឹកចិត្តឲ្យមានមនុស្សមករស់នៅឲ្យបានច្រើន។ ប្រជាជនមកពីច្រើនខេត្តផ្សេងៗគ្នា បានមករស់នៅ និងកសាងគ្រួសារនៅតំបន់អូរស្វាយ ព្រោះតំបន់នេះ សំបូរទៅដោយធនធានធម្មជាតិយ៉ាងច្រើនកុះករ។ សម្តេចនរោត្តម សីហនុ បានសាងសង់ផ្សារ សាលាស្រុក ព្រលានយន្តហោះ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ប៉ុន្តែក្រោយមក ត្រូវបានបាក់ធ្លាក់ចូលទន្លេ ហើយនៅសេសសល់តែស្តូបអនុស្សាវរីយ៍សម្តេចតា និងវិហារចាស់មួយតែប៉ុណ្ណោះ។ រហូតមកដល់សព្វថ្ងៃនេះ ប្រជាជននៅតែបន្តគោរពអុជធូប ថ្វាយបង្គំបួងសួង ដើម្បីឧទ្ទិសកុសលផលបុណ្យដល់អ្នកថែរក្សាទឹកដីនៅទីនោះតាមបែបប្រពៃណីពីដូនតាមក ។

ប្រជាជននៅតំបន់អូរស្វាយ ភាគច្រើនប្រកបរបរនេសាទត្រីដើម្បីចិញ្ចឹមជីវិត ហើយពីមុនប្រជាជនប្រើតែមង និងសន្ទូច ដើម្បីចាប់ត្រី។ តំបន់អូរស្វាយសម្បូរត្រីណាស់ ព្រោះតំបន់នេះនៅជាប់ទន្លេមេគង្គ។ ត្រីមួយក្បាលមានទម្ងន់រហូតដល់ ២០ ទៅ ៣០គីឡូក្រាម និងធំៗជាងនោះក៏មានច្រើនដែរ។ ត្រីនៅតំបន់អូរស្វាយមានច្រើនណាស់ សូម្បីតែខ្ញុំចុះហែលទឹកទន្លេក៏មិនចង់ហ៊ានចុះហែលទឹកផង ព្រោះត្រីធំៗពេក។ បើនិយាយពីត្រីរៀលវិញគរគ្នាត្រឹមជង្គង់ មិនដឹងយកទៅណាអស់ទេ។ ត្រីប៉ាសេអ៊ី ក៏មានច្រើនណាស់ដែរ។ ចំណែកត្រីត្រសក់ ធំៗប៉ុននឹងខ្លួនមនុស្ស ហើយត្រីខ្ទឹងមើលទៅហែលក្នុងទឹកដូចម្រាមដៃអ៊ីចឹង។ ប្រសិនបើយើងចង់ហូបកំពឹស យើងគ្រាន់តែយកឈ្នាងទៅជញ្ជាត់តែមួយភ្លែត នឹងបានកំពឹសពេញធុងហើយ។ រីឯផ្សោតវិញពេលហែលឡើងមកលើទឹកម្តងៗមានពី ៥០ ទៅ១០០

ក្បាល ប៉ុន្តែជាអកុសល កងទ័ពវៀតណាម បានបាញ់ផ្សោតលេងទុកជាការកម្សាន្ត ស្លាប់ឡើងពាយមួយថ្ងៃៗរាប់សិបក្បាល។

បច្ចុប្បន្ន ធនធានត្រី ផ្សោត និងរុក្ខជាតិក្នុងទឹកស្ទើរតែបាត់បង់អស់ទៅហើយ។ ត្រីប៉ាសេអ៊ី មានតែប៉ុនៗកដៃកូនក្មេងរកទិញហូបមិនចង់បានផង រីឯត្រីអំបូង ខ្ញុំខានឃើញជាច្រើនឆ្នាំមកហើយ។ ត្រីត្រសក់ក៏ប្រហែល ជាជិតផុតពូជដែរ។ អ្វីៗទាំងអស់សឹងតែបាត់បង់អស់ទៅហើយ ដោយសារតែបទល្មើសខុសច្បាប់កាន់តែកើនឡើង ហើយតម្រូវការប្រជាជនកាន់តែខ្ពស់ជាងមុន ។

ខ្ញុំបានឈប់នេសាទត្រីយូរដែរហើយ ព្រោះពេលដែលខ្ញុំទៅបង់សំណាញ់ម្តងៗរកតែត្រីមួយសម្លមិនចង់បានហូបផង។ ខ្ញុំឥឡូវហូបតែសាច់ជ្រូក មាន់ ទា ចំណែកឯត្រី ខ្ញុំបានទិញហូបម្តងម្កាលតែប៉ុណ្ណោះ។ ខ្ញុំនេសាទមិនសូវបាន ទើបធ្វើឲ្យប៉ះពាល់ដល់ចំណូលក្នុងគ្រួសារ។ ក្រោយមក ខ្ញុំបានងាកចេញពីការនេសាទទៅចិញ្ចឹមមាន់ទា និងដាំបន្លែ តែក៏មិនសូវបានផលទេ។

រំឭកដល់ឆ្នាំ១៩៧០ ភ្លើងសង្គ្រាមចាប់ផ្តើមឆេះឡើង លន់ នល់ បានវាយពីទីរួមខេត្តស្ទឹងត្រែងមករហូតទទួលបានជ័យជម្នះ ហើយបន្ទាប់មកទាហាន លន់ នល់ បានចូលមកកាន់កាប់នៅតំបន់អូរស្វាយ។ ទាហាន លន់ នល់ បានចាប់ខ្ញុំទៅកាន់ទីរួមខេត្តឲ្យធ្វើជាទាហាន។ កាលនោះ ខ្ញុំមិនចេះកាន់កាំភ្លើងទេ ដូច្នេះហើយទើបខ្ញុំលួចរត់មកអូរស្វាយវិញ ។

មិនយូរប៉ុន្មាន ខ្មែរក្រហមចូលមកដល់តំបន់អូរស្វាយ ប៉ុន្តែនៅក្នុងភូមិមិនមានភាពចលាចលអ្វីទេ ព្រោះខ្មែរក្រហមបានវាយបែកខេត្តស្ទឹងត្រែងមុនរួចទៅហើយ។ ពេលចូលមកកាន់កាប់ដំបូង ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើជាអ្នកដឹកជញ្ជូនស្រូវអង្ករពីខេត្តមួយទៅខេត្តមួយ និងពីតំបន់មួយទៅតំបន់មួយផ្សេងទៀត។ ខ្ញុំមិនបានរស់នៅតំបន់អូរស្វាយជាប់លាប់ទេ ព្រោះខ្ញុំជាអ្នកដឹកជញ្ជូនស្បៀងអាហារ។ ពេលខ្លះ ខ្ញុំត្រូវបានមេកងឲ្យទៅរាវមីននៅឯខេត្តសៀមរាបមួយរយៈពេលដែរ។ មួយខែក្រោយមក ខ្ញុំនៅតែដឹកជញ្ជូនតាមធម្មតា។នៅពេលខ្វះកងទ័ពម្តងម្កាល ខ្ញុំក៏បានចូលរួមជាមួយនឹងកងទ័ពខ្មែរក្រហមប្រយុទ្ធជាមួយសត្រូវរហូតត្រូវរបួសហើយបន្សល់ស្លាកស្នាមដល់សព្វថ្ងៃនេះ។

នៅតំបន់អូរស្វាយ មិនមានកន្លែងសម្លាប់មនុស្សជាក់លាក់ទេ។ ប្រជាជនមួយចំនួនធំ ត្រូវខ្មែរក្រហមយកទៅសម្លាប់ ប៉ុន្តែខ្ញុំមិនដឹងថាខ្មែរក្រហមយកទៅសម្លាប់នៅឯណាទេ ព្រោះតំបន់នេះសម្បូរទៅដោយព្រៃមិនសូវមានអ្នកដឹងទេ ឬពិបាកមើលឃើញណាស់នៅពេលដែលខ្មែរក្រហមបណ្តើរអ្នកទោសទៅសម្លាប់នោះ។ ខ្ញុំធ្លាប់បានឃើញខ្មែរក្រហមបណ្តើរ សែប អួន យកទៅសម្លាប់ និងចាក់សម្លាប់គាត់ ព្រោះ សែប អួន ជាអ្នកស្នេហាជាតិមិនចូលចិត្តរបបកុម្មុយនីស្ត ហើយសុខចិត្តស្លាប់មិនចូលរួមជាមួយក្រុមកុម្មុយនីស្តឡើយ។ ចំណែកឯ បងប្អូនជីដូនមួយរបស់ខ្ញុំម្នាក់ បានស្លាប់ដោយសារតែត្រូវគ្រាប់ដាច់ខ្លួនជាពីរយ៉ាងអាណោចអាធ័ម ។

យើងគ្មានពេលសប្បាយរីករាយទេ ពេលវេលារបស់យើងពោរពេញទៅដោយភាពហត់នឿយ ភ័យខ្លាច ព្រួយបារម្ភ ដោយមិនដឹងថាយើងអាចរស់បានដល់ថ្ងៃណាទេ។ យើងធ្វើអ្វីត្រូវតែប្រុងប្រយ័ត្នគ្រប់ជំហានទាំងអស់។ អ្វីដែលខ្ញុំចងចាំមិនអាចបំភ្លេចបាននោះគឺ រឿងដែលខ្មែរក្រហមកាប់សម្លាប់មនុស្សគ្មានប្រណី ហើយភាពភ័យខ្លាចនេះ នៅតែបន្តជិតដាមជាមួយការចងចាំរបស់ខ្ញុំរហូតមកដល់ពេលបច្ចុប្បន្ន ។

សព្វថ្ងៃនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅបន្តរងឥទ្ធិពលពីអតីតកាល និងប្រឈមមុខនឹងបញ្ហាអភិវឌ្ឍន៍វារីអគ្គិសនីនៅតាមដងទន្លេមេគង្គ។ ខ្ញុំនៅសល់ស្លាកស្នាមរបួសផ្លូវចិត្តដែលបាក់ស្បាតពីសង្គ្រាម និងខ្វះចំណូលប្រចាំថ្ងៃ ព្រោះខ្ញុំរកត្រីមិនបានដូចមុនទៀតទេ។ ខ្ញុំក៏មានក្តីបារម្ភដែរ នៅពេលដែលខ្ញុំរស់នៅក្រោមទំនប់វារីអគ្គិសនី ព្រោះទំនប់វារីអគ្គិសនីនោះធ្លាប់បាក់ ហើយធ្វើឲ្យប៉ះពាល់ប្រជាជនជាខ្លាំង។

# ជា ចាន់ន្ថាយ ៖ អតីតអ្នកធ្វើព្រះក្រយាថ្វាយ សម្តេចតាសម្តេចយាយ

### អត្ថបទដោយ ៖ ស្រេង លីដា

ខ្ញុំឈ្មោះ **ជា ចាន់ន្ថាយ** អាយុ ៧០ឆ្នាំ ខ្ញុំកើតនៅឆ្នាំ១៩៥៦ ឪពុករបស់ខ្ញុំឈ្មោះ ជា ពេញ ស្លាប់នៅឆ្នាំ១៩៦៨ ចំណែកម្តាយរបស់ខ្ញុំឈ្មោះ អ៊ុង កាយ ស្លាប់នៅឆ្នាំ២០០២។ ខ្ញុំមានបងប្អូនចំនួន ៥នាក់ ហើយខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។ ប្អូនទី២ របស់ខ្ញុំឈ្មោះ ជា ចាន់ធឿន (ស្រី) ប្អូនទី៣ ឈ្មោះ ជា សុភាព (ស្រី) ចំណែកឯប្អូនទី៤ ឈ្មោះ ជា គឹមស្រ៊ុន ស្លាប់នៅឆ្នាំ១៩៧៩ និងប្អូនទី៥ ឈ្មោះ ជុំ គឹមសៀង។ សព្វថ្ងៃ ខ្ញុំជាគ្រូបង្រៀន។ ខ្ញុំមានជំងឺប្រចាំកាយជាជំងឺលើសឈាម តែបានលេបថ្នាំជាប្រចាំ ។ ខ្ញុំបង្រៀនតាំងពីក្រោយរំដោះឆ្នាំ១៩៧៩ មក ដោយសារមេភូមិ បានហៅឲ្យខ្ញុំមកជួយបង្រៀនដល់ក្មេងៗដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ ប្តីរបស់ខ្ញុំឈ្មោះ ស៊ី អឿន មានស្រុកកំណើតនៅខេត្តស្ទឹងត្រែង។ សព្វថ្ងៃខ្ញុំមានកូនចំនួន ៥នាក់ កូនទី១ រស់នៅខាងផ្លូវអាស៊ាន (ស្រី) កើតនៅឆ្នាំ១៩៧៧ កូនទី២ កើតនៅភូមិអូរស្វាយ ឈ្មោះថា ស៊ី គឹមស្រ៊ួន (ប្រុស) កូនទី៣ ឈ្មោះថា ស៊ី គឹមស្រឿន (ស្រី) កើតនៅឆ្នាំ១៩៨៥ កូនទី៤ ឈ្មោះថា ស៊ី គឹមឌី បានចូលធ្វើជាទាហាន និងកូនទី៥ ធ្វើការងារខាងបរិស្ថាននៅតាមព្រំដែនវៀតណាម។ ខ្ញុំបានមករស់នៅអូរស្វាយ នៅឆ្នាំ១៩៦៨ ដោយសារឪពុករបស់ខ្ញុំបានមកចាប់ដីពេលសម្តេចតាបានអំពាវនាវថា ឲ្យបងប្អូនប្រជាជនខ្មែរមករស់នៅស្ទឹងត្រែង ដែលមានមកពីខេត្តតាកែវ ព្រៃវែង ក្រចេះ កំពង់ចាម ភាគច្រើនតាកែវ ព្រៃវែង និយាយទៅមានគ្រប់ខេត្តក្រុង។សម្តេចតាបានចែកដីឡូត៍ឲ្យក្នុងមួយគ្រួសារ មានទទឹង ៤០ម៉ែត្រ និងបណ្តោយ ៥០ម៉ែត្រ។ លើសពីនេះ សម្តេចតា បានជួយផ្គត់ផ្គង់ប្រជាជននៅទីនេះប្រហែលជា ១ឆ្នាំ និងបានចែកដូងប្រេងក្នុងមួយគ្រួសារ ១០ដើម និងចែកសត្វគោក្នុងមួយគ្រួសារ ២ក្បាលសម្រាប់ចិញ្ចឹម។ ឪពុករបស់ខ្ញុំនិយាយថា សម្តេចតាមានឧត្តមគតិខ្ពស់ណាស់។ កាលពីមុនគ្មានប្រជាជនមករស់នៅតាមព្រំដែនទេ ដូច្នេះទើបសម្តេចតា អំពាវនាវឲ្យប្រជាជនមករស់នៅតាមជាយព្រំដែនជាមួយឡាវ។ សម្តេចតា ចង់នាំប្រជាជនមករស់នៅតាមព្រំដែន ព្រោះខ្លាចឡាវជ្រៀតជ្រែកព្រំដែនរំកិលចូលមក។ កាលណាមានប្រជាជនមករស់នៅជាប់ព្រំដែន សម្តេចតា បានសាងសង់បន្ទាយទាហាន និងបង្កើតជាភូមិ ដើម្បីកុំឲ្យឡាវអាចរំកិលមកបាន។ ខ្ញុំបានមករៀននៅអនុវិទ្យាល័យសាលាខេត្តស្ទឹងត្រែង។ ខ្ញុំមិនបានរៀនចប់អនុវិទ្យាល័យនោះទេ ដោយសារឪពុករបស់ខ្ញុំស្លាប់ ទើបខ្ញុំឈប់រៀន។ ពេលនោះ ម្តាយរបស់ខ្ញុំមិនចង់ឲ្យខ្ញុំឈប់រៀននោះទេ ប៉ុន្តែ ខ្ញុំបារម្ភខ្លាចគាត់គ្មានលុយឲ្យខ្ញុំរៀនបន្ត។ម្យ៉ាងទៀតម្តាយរបស់ខ្ញុំត្រូវចិញ្ចឹមកូនៗច្រើននាក់ទៀតផង។

ខ្ញុំមកដល់អូរស្វាយដំបូង មានការរៀបចំអភិវឌ្ឍន៍ល្អណាស់។ លោក ម៉ៅ សាក់ផេន បានរៀបចំផែនការ ៥ឆ្នាំ នៅតំបន់អូរស្វាយ រួមមាន ការកសាងសាលារៀន មន្ទីរពេទ្យ និងផ្ទះកាឡុង។ ឆ្នាំ១៩៦៨ សម្តេចតាយាងមកសម្ពោធសាលាធទាន សាលារៀន មន្ទីរពេទ្យ បន្ទាយទាហាន សួនច្បារ និងកន្លែងដំណាក់មាត់ទឹក។ ប្រសិនបើគ្មានសង្គ្រាមនៅឆ្នាំ១៩៧០ នោះទេ តំបន់អូរស្វាយនឹងសម្បូរសប្បាយណាស់។ អំឡុងឆ្នាំ១៩៧៣ ពេលដែលសម្តេចតា យាងមកតំបន់អូរស្វាយ ខ្ញុំបានចូលទៅបម្រើសម្តេចតា និងពួមិត្តៗ និយាយគ្នាថា «យើងប្រហែលជាមិនបានចូលឆ្នាំទេ ឬអាចចូលឆ្នាំនៅក្នុងព្រៃ» ។

គ្រាមួយនោះ សម្តេចតា សម្តេចយាយ បានយាងចូលមកដល់ទឹកដីខ្មែរ ក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង រួចទ្រង់បានគង់នៅទីនោះ លុះស្អែកឡើងទ្រង់បន្តយាងទៅព្រៃទទឹង (ព្រៃចាស់)។ នៅព្រៃទទឹងមានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំង ដូច្នោះហើយទើបទ្រង់សម្រេចចិត្តរៀបចំអីវ៉ាន់ចេញពីព្រៃទទឹង នៅម៉ោង ៧យប់ ហើយក៏បានធ្វើដំណើរឆ្លងកាត់កំពង់ចម្លងពាណិជ្ជកម្ម ស្រុកថាឡាបរិវ៉ាត់។ ពេលនោះ ខ្ញុំនៅចង្ក្រានបាយជួយធ្វើម្ហូបថ្វាយទ្រង់ពេលធ្វើដំណើរ។ ឡានរបស់សម្តេចតា និងកងការពារបានចេញទៅមុន។ ចំណែក

ឡានចង្រ្កានបាយ មានឡានកងការពារចំនួន ៣ឡាន នៅការពារតាមពីក្រោយ។ នៅពេលនោះ ហម មុន្នី គឺជាមេចុងភៅ។ ម្ហូបសម្រាប់ថ្វាយ សម្តេចតា សម្តេចយាយ តែងតែផ្លាស់ប្តូរហូត ដូចជា ម្ហូបខ្មែរ ម្ហូបបារាំង ដែលក្នុងមួយពេលមានពី ៧ ទៅ ៨មុខ។ សម្រាប់ភ្ញៀវពិសេសៗ ថ្នាក់ដឹកនាំធំៗផ្សេងទៀត ម្ហូបត្រូវរៀបចំមួយពេលពី ៣ ទៅ ៤ មុខ និងមានការផ្លាស់ប្តូរមុខម្ហូបទៅតាមនោះដែរ។

សម្តេចតា សម្តេចយាយ ធ្វើដំណើរចេញពីស្រុកសៀមប៉ាង ឆ្ពោះទៅជើងភ្នំគូលែន តែពេលយប់នោះទេ ហើយឡានធ្វើដំណើរទាំងអស់បានបិទភ្លើង ព្រោះខ្លាចខ្មាំងវាយប្រហារបង្កឲ្យមានគ្រោះថ្នាក់។ ពេលធ្វើដំណើរឡើងផុតពីស្ទឹងសែន ខ្មាំងបានបាញ់គ្រាប់ ៧១៣០ មក។ ពេលយន្តហោះបាញ់នោះ ខ្ញុំកំពុងតែដេកនៅលើឡាន ព្រោះខ្ញុំអត់ងងុយពេក ហើយអ្នកផ្សេងរួមទាំងកងការពារ បាននាំគ្នាចុះពីលើឡាន រត់ទៅក្រាបពួននៅក្នុងព្រៃ។ ពេលនោះ គ្រូពេទ្យផ្ទាល់របស់សម្តេចតា បានបញ្ជាំងពិលមើលយុវជន យុវនារី ឃើញថា បាត់តែខ្ញុំម្នាក់ក្នុងចំណោមមនុស្សទាំងអស់។ គាត់បានឲ្យកងការពារមករកមើលខ្ញុំ ហើយប្រធានទ័ព បានស្រែកហៅឈ្មោះរបស់ខ្ញុំឮៗ។ រំពេចនោះ ខ្ញុំក៏ស្ទុះភ្ញាក់ឡើងស្រប ពេលដែលយន្តហោះកំពុងតែបាញ់។ ខ្ញុំភ័យពេកលោតចុះពីលើឡានធ្វើឲ្យរបួសជើង ហើយពេទ្យបានសួរខ្ញុំថា ជើងមិត្តនារីកើតអី? ព្រោះពេទ្យបារម្ភខ្លាចខ្ញុំត្រូវគ្រាប់។ ពេលយន្តហោះបាញ់ កងការពារផ្ទាល់របស់សម្តេចតា និងខាងចង្រ្កានបាយ គ្មាននរណាម្នាក់មានគ្រោះថ្នាក់ឡើយ។ ខ្ញុំមានរបួសជើងបន្តិច ដោយសារលោតចុះពីលើឡាន ហើយពេទ្យបានដាក់សេរ៉ូមនៅតាមឡានឲ្យខ្ញុំរហូតទៅដល់ជើងភ្នំគូលែន។ ខ្ញុំបានថតរូបជាមួយសម្តេចតា សម្តេចយាយ នៅលើភ្នំគូលែន និងបានលេងទឹកជ្រោះនៅទីនោះដែរ ។ ពេលថតកុនរួច សម្តេចតា សម្តេចយាយ ក៏បានបន្តធ្វើដំណើរទៅសៀមរាបអង្គរវត្ត។ បន្ទាប់ពីនោះមក សម្តេចតា សម្តេចយាយ បានយាងត្រលប់ទៅប៉េកាំងវិញ ហើយពួកខ្ញុំកងការពារក៏ត្រលប់មកផ្ទះសម្បែងរៀងៗខ្លួនដែរ។ ពេលបែកពីសម្តេចតា សម្តេចយាយ មក ខ្ញុំមិនបានត្រលប់ទៅរស់នៅតំបន់អូរស្វាយវិញទេ។ ខ្ញុំបាននៅមន្ទីរអង្គភាព។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំនៅកងចល័ត។ ខ្ញុំធ្វើការនៅកងចល័តមិនបានប៉ុន្មានផង ខ្ញុំក៏ប្តូរទៅនៅកងសិល្បៈហូត។ មនុស្សគ្រប់គ្នាជួបផលវិបាកសូម្បីតែនិយាយគ្នាក៏ពុំបានឡើយ។ យើងរស់មួយថ្ងៃគិតមួយថ្ងៃ ប្រៀបដូចមាន់នៅក្នុងទ្រុងគ្មានសេរីភាព គ្មានសេចក្តីសុខឡើយ។ ខ្មែរក្រហមបានធ្វើទារុណកម្ម ដោយមិនឲ្យហូបគ្រប់គ្រាន់ និងធ្វើការលើសកម្លាំង ដូចជាលើកទំនប់ លើកប្រព័ន្ធភ្លឺស្រែ និងធ្វើស្រែចម្ការ។ ពេលនោះ ខ្ញុំនៅភូមិភាគឦសាន មានលក្ខណៈធូរបន្តិច។ ខ្មែរក្រហមឲ្យបាយហូបកន្លះកំប៉ុងសម្រាប់មនុស្សច្រើននាក់ពិតមែន តែមានដំឡូងមី ពោត សណ្តែកក្រហម ឬសណ្តែកបាយថែមទៀត។ យើងត្រូវធ្វើស្រូវមួយឆ្នាំ ៣ដង ហើយជង្រុកស្រូវមានប្រវែងប្រហែល ១០ម៉ែត្រ ដាក់ស្រូវពេញៗ ប៉ុន្តែខ្មែរក្រហមមិនឲ្យយើងហូបឆ្អែតទេ។ គ្រួសាររបស់ខ្ញុំជួបការលំបាកច្រើនណាស់។ ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមយកទៅវាយចោល ដោយចោទថា គាត់ជាខ្មែរយួន។ តាំងពីពេលនោះមក ខ្ញុំត្រូវបានចោទប្រកាន់ថាជាប់ជាខ្សែក្បត់ ត្រូវខ្មែរក្រហមតាមដានទាំងយប់ទាំងថ្ងៃជាប់រហូត។ ខ្ញុំមិនហ៊ានឲ្យអ្នកណាដឹង និងនិយាយលើកតម្កើងពីប្រវត្តិខ្លួនឯងឡើយ សូម្បីតែកម្រិតវប្បធម៌ ក៏ខ្ញុំប្រាប់មេកងថា ខ្ញុំរៀនបានត្រឹមថ្នាក់ទី១១ដែរ។ ក្រោយមក មេកងបានបញ្ជូនខ្ញុំទៅតំបន់អូរពងមាន់រយៈពេលមួយខែ ដោយបាយមិនឲ្យហូប ហើយពេលឈឺក៏គ្មានពេទ្យព្យាបាលដែរ។ ពេលនោះ មនុស្សនៅក្នុងក្រុមមន្ទីរសិល្បៈរបស់ខ្ញុំក៏ត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ទាំងប្រុសទាំងស្រី ដោយចោទប្រកាន់ថាជាប់ខ្សែយួន។ បើគ្រួសារខាងប្តីរបស់ខ្ញុំ ឪពុកមា និងបងប្អូនជីដូនមួយ ត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងអស់ស្ទើរតែផុតពូជ។ ប្តីរបស់ខ្ញុំក៏ខ្មែរក្រហមយកទៅសម្លាប់ដែរ តែសំណាងល្អបានមេកងរបស់គាត់មានចិត្តល្អមេត្តាអាណិតអាសូរ ក៏បានទៅធានាខ្លួនប្តីរបស់ខ្ញុំចេញមកបាន។ ក្រោយមក ពេលខ្ញុំមានផ្ទៃពោះកូនច្បង ខ្ញុំបានទៅសម្រាកនៅមន្ទីរពេទ្យភូមិភាគ ហើយខ្មែរក្រហមបានមកយកប្តីរបស់ខ្ញុំម្តងទៀត តែបានបងចាន់ធី ជួយចេញមុខទទួលខុសត្រូវ។ បងចាន់ធីសុខចិត្តស្លាប់ជំនួសប្តីរបស់ខ្ញុំ ។ ចុងក្រោយ ខ្មែរក្រហមមកយកប្តីរបស់ខ្ញុំម្តងទៀត តែបានលោកគ្រូបង្រៀនម្នាក់ចេញមុខមកជួយជាមួយប្រធានកងចល័តរបស់គាត់ ។ ពេលមានការរំដោះថ្ងៃ ៧ មករា មក ខ្ញុំបានរត់ពួននៅក្នុងព្រៃតាមជ្រលងភ្នំនៅខេត្តរតនគិរី។ កាលនោះមានមនុស្សមួយក្រុមមកឃោសនាថា មានវៀតណាមចូលមកប្រទេសកម្ពុជាយើងហើយ ប៉ុន្តែខ្ញុំក៏នៅតែមិនហ៊ានចេញពីព្រៃឡើយ។ ថ្ងៃមួយ ខ្ញុំបានជួបកងទ័ពវៀតណាមនៅក្នុងព្រៃឫស្សីពេលដែលខ្ញុំកំពុងតែដាំបាយ។ កងទ័ពវៀតណាមម្នាក់បានចាប់កូនច្បងរបស់ខ្ញុំព ធ្វើឲ្យខ្ញុំភ័យ

ខ្លាំងណាស់។ កងទ័ពវៀតណាមប្រាប់ថា ឲ្យខ្ញុំចេញពីព្រៃទៅស្រុកកំណើតវិញចុះ គ្មាននរណាធ្វើអ្វីឡើយ។

ខ្ញុំបានមកដល់តំបន់អូរស្វាយ ហើយខ្ញុំក៏បានឈប់សម្រាកនៅទីនោះ។ ប្រជានភូមិប្រាប់ខ្ញុំថា កុំទាន់ធ្វើដំណើរទៅខេត្តស្ទឹងត្រែង ព្រោះខ្លាចមានការវាយគ្នានៅតាមផ្លូវ។ មួយឆ្នាំក្រោយមក មេភូមិបានជ្រើសរើសគ្រូបង្រៀននៅអូរស្វាយ ហើយខ្ញុំបានសម្រេចចិត្តធ្វើគ្រូបង្រៀននៅអូរស្វាយរហូតមក។ ខ្ញុំតស៊ូបង្រៀននៅក្រោមម្លប់ដើមស្វាយដោយគ្មានប្រាក់ខែឡើយ។ ជំនួយការវៀតណាមឃើញដូច្នោះ ក៏អាណិត ហើយបានឧបត្ថម្ភជាអង្ករ ១២គីឡូក្រាម ក្នុង ១ខែ ដល់ខ្ញុំ។ ខ្ញុំបានតស៊ូបង្រៀនរហូតដល់ចូលនិវត្តន៍។

កាលខ្ញុំមកដល់អូរស្វាយ ក្រោយថ្ងៃរំដោះ ១៩៧៩ មក យើងមិនទាន់មានអ្វីទេ។ ប្រជាជននៅក្រខ្សត់ សូម្បីតែជីវភាពរស់នៅពិបាកគ្មានស្បៀងអង្ករឡើយ។ ក្រោយមកបានមួយឆ្នាំ ប្រជាជនក៏ចាប់ផ្តើមធូរជារ ធ្វើស្រែចម្ការ ដាំដំណាំរហូតដល់សព្វថ្ងៃ។ គ្រួសាររបស់ខ្ញុំប្រកបរបរនេសាទត្រីបង់សំណាញ់ និងដាក់សន្ទូចបន្ថិចបន្តួចសម្រាប់ហូបប្រចាំថ្ងៃ ។

ជាចុងក្រោយ នាងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាល អាជ្ញាធរពាក់ព័ន្ធ និងប្រជាជនទាំងអស់ សូមចូលរួមការពារ និងអភិរក្សធនធានធម្មជាតិ និងត្រីកម្រ ដែលកំពុងប្រឈមនឹងការបាត់បង់ឲ្យមានការកើនឡើងវិញ។

# ស្រេង ទិត្យ ៖ រស់ដោយសារនេសាទត្រី

## អត្ថបទដោយ ៖ ស្រេង លីដា

ខ្ញុំឈ្មោះ **ស្រេង ទិត្យ** អាយុ ៥១ឆ្នាំ ភេទប្រុស មានស្រុកកំណើតនៅភូមិក្រឡាពាស ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំមានបងប្អូន ៥នាក់ ស្រី ១នាក់ ហើយខ្ញុំជាកូនច្បងក្នុងគ្រួសារ។ បងប្អូនរបស់ខ្ញុំរស់នៅឃុំព្រះរំកិលទាំងអស់ មានតែខ្ញុំម្នាក់ទេដែលមករស់នៅអូរស្វាយនេះតែម្នាក់ឯង។ ឪពុករបស់ខ្ញុំបានស្លាប់យូរហើយ នៅតែម្តាយ។ ខ្ញុំមានកូន ៤នាក់ ប្រុស ៣នាក់ ស្រី ១នាក់ ។

នៅពេលដែលខ្មែរក្រហមចូលមកដល់អូរស្វាយ ខ្ញុំនៅតូចនៅឡើយ។ ខ្មែរក្រហម បានជម្លៀសប្រជាជនដែលនៅព្រះរំកិល រួមទាំងក្រុមគ្រួសាររបស់ខ្ញុំឲ្យទៅរំដេង អូររុន ចម្ការលើ ហើយអ្នកដែលនៅក្នុងភូមិទាំងអស់នោះ ត្រូវខ្មែរក្រហមជម្លៀសឲ្យមកនៅព្រះរំកិលវិញ។ ខ្ញុំមិនទាន់ចេះធ្វើការអ្វីទេនៅពេលនោះ។ ខ្មែរក្រហម បានឲ្យខ្ញុំមើលតែក្មេងតូចៗ។ ចំពោះការហូបចុកវិញ ខ្ញុំមិនដែលបានហូបគ្រប់គ្រាន់ទេ គឺមានតែបបរលាយដើមចេក មើមល្ហុង និងមើមរុក្ខជាតិផ្សេងៗទៀត។ ចុងភៅឲ្យអ្វីយើងហូប ក៏ចេះតែហូបទៅតាមនោះ។ យើងមិនអាចប្រកែកតវ៉ាបានទេ ហើយម្យ៉ាងទៀត យើងស្រែកឃ្លានណាស់។ ក្នុងមួយថ្ងៃ យើងទទួលបានអាហារតែពីរពេលទេ គឺពេលថ្ងៃ និងពេលល្ងាច ហើយក្នុងមួយពេលបានតែមួយចានចង្កឹះតែប៉ុណ្ណោះ។ ពេលខ្លះខ្ញុំឃ្លានពេក ក៏ទៅលួចបាយជ្រូកមកហូបក៏មានដែរ ។

ក្នុងឆ្នាំ១៩៧៩ ប្រទេសកម្ពុជា ត្រូវបានរំដោះដោយកងទ័ពវៀតណាម។ ខ្មែរក្រហមបានជម្លៀសខ្ញុំពីអូររុនខាងចម្ការលើមកព្រះរំកិលវិញ។ ខ្មែរក្រហមបានដឹកជញ្ជូនគ្រួសាររបស់ខ្ញុំតាមទូក ហៅថា អាសែងសង។ ពេលមកដល់ព្រះរំកិល ខ្ញុំមិនសូវបានរៀនសូត្រទេ។ ពេលខ្លះ ក៏បានរៀន ពេលខ្លះក៏អត់ ហើយយើងរៀននៅក្រោមដើមឈើ និងមិនបានជិតដល់អ្វីទេ ដូច្នេះហើយខ្ញុំមិនចេះអក្សរទេសព្វថ្ងៃនេះ ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់បងម្នាក់ឈ្មោះ ញៀន ចៀម។ ពេលនោះ មេកងថា យកបងរបស់ខ្ញុំទៅកុមារឈានមុខ ហើយក្រោយមក ស្រាប់តែបាត់ដំណឹងសូន្យឈឹងមកដល់សព្វថ្ងៃនេះ មិនដឹងថាគាត់បានជួបរឿងអ្វីខ្លះនោះទេ។

ក្រោយខ្មែរក្រហមដួលរលំ ប្រជាជននាំគ្នាត្រលប់មកនៅអូរស្វាយវិញ។ ខ្ញុំត្រលប់មកវិញរកស៊ីនេសាទត្រីលក្ខណៈគ្រួសាររហូតមកទាល់សព្វថ្ងៃនេះ។ កាលពីមុន ត្រីសម្បូរណាស់ ត្រីប្រភេទណាក៏មានដែរ។ ប្រជាជនឡាវ និងវៀតណាម ក៏ចូលមកនេសាទត្រីដែរ ហើយប្រជាជនឡាវ និងវៀតណាម មានបច្ចេកទេសនេសាទ ទើបចាប់ត្រីបានធំៗ និងច្រើនជាងយើង។ ផ្ទុយទៅវិញ សព្វថ្ងៃនេះ ត្រីអាចនៅសល់ត្រឹមតែ ៣០ភាគរយនោះទេ។ ត្រីធំៗ បាត់បង់ ៩០ភាគរយទៅហើយ។ ត្រីហិនហោចនេះមកពីកត្តាជាច្រើនយ៉ាងរួមមាន តម្រូវការខ្ពស់ ប្រជាជនកាន់តែច្រើន ទឹកទន្លេមិនទៀងទាត់ ដែលបណ្ដាលមកពីការសាងសង់ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេគ្គកាន់តែច្រើន ព្រៃលិចទឹកដែលជាជម្រកត្រីងាប់ និងការនេសាទខុសច្បាប់មិនអាចបង្រ្កាបបានអស់ ។

ក្រុមគ្រួសាររបស់ខ្ញុំរស់នៅពឹងផ្អែកទៅលើការនេសាទទាំងស្រុង។ ខ្ញុំចិញ្ចឹមកូនតាំងពីតូចរហូតដល់ធំបានរៀនសូត្រក៏ដោយសារនេសាទត្រីនេះដែរ។ តាំងពីដើមមកខ្ញុំមិនដែលទៅធ្វើអ្វីទេ គឺប្រកបរបរនេសាទតែមួយមុខ តែមកដល់ឥឡូវនេះ ក្រុមគ្រួសាររបស់ខ្ញុំពិបាកណាស់ ដោយសារនេសាទត្រីមិនបានដូចពីមុនឡើយ ។

# ខ្មែរក្រហមបង្ខំឲ្យខ្ញុំរៀបការ៣ដង

## អត្ថបទដោយ ៖ ស្រេង លីដា

ខ្ញុំឈ្មោះ **មុិច សុីណា** ភេទស្រី អាយុ ៦២ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ចាម។ ពេលខ្ញុំមានអាយុប្រហែល ១០ឆ្នាំ ខ្ញុំបានមករស់នៅភូមិកោះញ៉ែតាមឪពុកម្ដាយរបស់ខ្ញុំរហូតមកដល់សព្វថ្ងៃនេះ។ ខ្ញុំមានបងប្អូន ៨នាក់ ស្រី ៦នាក់ ប្រុស ២នាក់( ស្លាប់ទាំងពីរ )។ វ័យកំពុងតែពេញសប្បាយ ស្រុកទេសកំពុងតែរីកចម្រើន និងសម្បូរសប្បាយនៅក្នុងសម័យសង្គមរាស្ត្រនិយម បែរជាត្រូវធ្លាក់ក្នុងសង្គ្រាមស៊ីវិល គឺរបប លន់ នល់ និងរបបខ្មែរក្រហម។ ចូលមកដល់សម័យខ្មែរក្រហម ខ្ញុំមានតួនាទីជាកុមារឈានមុខ។ ខ្ញុំក៏ដូចជាកុមារដទៃទៀតរស់នៅព្រាត់ប្រាស់គ្រួសារគ្មានឡើយការជួបជុំបងប្អូន និងភាពរីករាយដូចមុនទៀតទេ។ វ័យកំពុងពេញលូតលាស់នៅជាកុមារភាពនៅឡើយ ប៉ុន្តែយើងត្រូវដើរនៅតាមកងកុមារ ធ្វើការជាទម្ងន់ដូចមនុស្សធំ។ យើងត្រូវបានខ្មែរក្រហមបង្ខំឲ្យលើកទំនប់ពីមួយកន្លែងទៅមួយកន្លែងផ្សេងទៀត និងបង្ខំឲ្យធ្វើការងារដោយគ្មានការយោគយល់ ឬអធ្យាស្រ័យអ្វីទាំងអស់។ ខ្ញុំធ្លាប់បានទៅលើកដីនៅត្រង់ចំណុចទំនប់អូរពូក ហើយខ្ញុំមិននៅធ្វើតែមួយកន្លែងនោះទេ។ ក្រោយមក ខ្ញុំត្រូវជម្លៀសទៅកន្លែងផ្សេងៗគ្នាទៀត។ ខ្មែរក្រហម បង្ខំឲ្យខ្ញុំធ្វើការដោយមិនខ្វល់ថា ចាស់ ឬក្មេងនោះទេ ហើយការផ្គត់ផ្គង់ការហូបចុកក៏មិនគ្រប់គ្រាន់ដែរ។ ខ្មែរក្រហមបានឲ្យជំឡូង៣មើម ដល់កុមាររាល់មួយសប្តាហ៍ម្តង ដើម្បីជប់លៀងក្នុងកងកុមារ។

ពេលវេលាមួយ ខ្ញុំមិនអាចបំភ្លេចបានក្នុងមួយជីវិតរបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហមនោះគឺ ខ្មែរក្រហមបានចាប់បង្ខំខ្ញុំឲ្យរៀបការនៅអាយុ ១២ឆ្នាំ មួយដងជាពីរដងមិនបានសម្រេច រហូតដល់បង្ខំខ្ញុំឲ្យរៀបការជាលើកទីបី ទើបខ្ញុំយល់ព្រម ព្រោះខ្ញុំខ្លាចស្លាប់។ នៅពេលដែលខ្មែរក្រហមចាប់បង្ខំឲ្យខ្ញុំរៀបការលើកទី១នោះ ខ្មែរក្រហមបានកុហកខ្ញុំថា ម្តាយរបស់ខ្ញុំឈឺ ដូច្នេះខ្ញុំត្រូវទៅមើលគាត់ ប៉ុន្តែមិនពិតនោះទេ គឺខ្មែរក្រហមបានកុហកខ្ញុំដើម្បីចាប់បង្ខំខ្ញុំឲ្យរៀបការ។ នៅពេលដែលខ្ញុំដឹងថាជាការកុហក ខ្ញុំក៏យំ និងប្រកែកមិនព្រមទៅទេ។ មេកងបានយកក្រមាមកទាក់ខ្ញុំ អូសទៅបានដល់ពាក់កណ្ដាលផ្លូវ មានអ្នកមកប្រាប់ថា កុំឲ្យយកខ្ញុំទៅរៀបការអី ព្រោះស្នែកឡើង បុរសដែលត្រូវរៀបការជាមួយខ្ញុំនោះនឹងត្រូវខ្មែរក្រហមយកទៅសម្លាប់ហើយ។ ខ្ញុំក៏បានរួចខ្លួនលើកទី១។

ក្រោយមក ខ្ញុំត្រូវខ្មែរក្រហមឲ្យទៅលើកទំនប់ដោយប្រើខ្ញុំឲ្យរែកដី និងអូសទឹក។ ខ្ញុំឈឺស្មាផង និងហើមផង។ ពេលនោះ ខ្មែរក្រហម បានបង្ខំខ្ញុំឲ្យរៀបការជាលើកទី២។ ខ្ញុំបដិសេធមិនព្រមរៀបការដូចលើកទី១ដែរ តែខ្មែរក្រហមបានមកអូសខ្ញុំ និងចោទប្រកាន់ខ្ញុំថា បើខ្ញុំមិនព្រមការជាមួយខ្មែរ មានតែចាំរៀបការជាមួយយួន។ ម្យ៉ាងវិញទៀត ខ្មែរក្រហម គំរាមថា បើខ្ញុំមិនព្រមរៀបការ នោះនឹងសម្លាប់បងរបស់ខ្ញុំចោល។ ព្ដូចនេះ ខ្ញុំក៏ព្រមរៀបការតាមការបង្ខំរបស់ខ្មែរក្រហម។ រៀបការហើយ យើងក៏បែកគ្នា ដោយសារតែប្ដីរបស់ខ្ញុំត្រូវទៅធ្វើជាកងទ័ព ហើយខ្ញុំត្រូវបន្តដើរនៅតាមកងកុមារធ្វើការលើកទំនប់ដូចរាល់ដង។ រំលងមកបានពីរទៅបីខែ ខ្ញុំត្រូវខ្មែរក្រហមចាប់បង្ខំឲ្យរៀបការជាលើកទី៣ទៀត ហើយក្រោយមកយើងបានបែកគ្នាទៀតដោយសារប្ដីរបស់ខ្ញុំ ត្រូវជាប់កាតព្វកិច្ចទៅធ្វើជាកងទ័ពខ្មែរក្រហមបាត់ដំណឹងសូន្យឈឹង។ មួយឆ្នាំក្រោយមក ប្ដីរបស់ខ្ញុំហែលទឹកត្រលប់មករកខ្ញុំវិញ ហើយយើងក៏បានរួមរស់ជាមួយគ្នារហូតដល់បានកូន ៧នាក់ ។

ក្រោយរំដោះឆ្នាំ១៩៧៩ ខ្ញុំក៏ដូចជាអ្នករស់នៅលើកោះដទៃទៀតដែរ យើងប្រកបរបរនេសាទ និងចិញ្ចឹមសត្វដើម្បីផ្គត់ផ្គង់គ្រួសារ។ សព្វថ្ងៃនេះ ការនេសាទមានការលំបាកណាស់ ដោយសាររកត្រីមិនសូវបានដូចពីមុនទេ។ ខ្ញុំសំណូមពរឲ្យអាជ្ញាធរពាក់ព័ន្ធមានការយោគយល់ខ្លះដល់អ្នកនេសាទតូចតាចមានឱកាសឲ្យពួកខ្ញុំបាននេសាទរយៈពេលពីរបីថ្ងៃនៅរដូវបិទការនេសាទដើម្បីបានត្រីហូប និងបានលក់ដូរខ្លះផង ។

# ខ្ញុំមានសំណាងបានមករស់នៅតំបន់អូរស្វាយ

## អត្ថបទដោយ ៖ ស្រេង លីដា

ខ្ញុំឈ្មោះ **ឆុន ឆោម** ភេទប្រុស អាយុ ៦១ឆ្នាំ មានឪពុកឈ្មោះ អ៊ុំ ឈាន ម្ដាយឈ្មោះ អែល លឿង។ ខ្ញុំមានបងប្អូនចំនួន ៦នាក់ ប្រុស ៥នាក់ ស្រី ១នាក់។ ខ្ញុំជាកូនទី៤ មានភរិយាឈ្មោះ ឈូក សុននារី មានកូន ៦នាក់ ស្រី ៤នាក់ និងប្រុស ២នាក់។ ខ្ញុំបានរៀនសូត្រត្រឹមថ្នាក់ទី៥។ ខ្ញុំកើតនៅខេត្តកំពង់ចាម ហើយបច្ចុប្បន្នរស់នៅភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំមករស់នៅតំបន់អូរស្វាយតាំងពីឆ្នាំ ១៩៨២ មកម្ល៉េះ។

ពេលរបប លន់ នល់ ចូលមកដល់ ខ្ញុំរស់នៅខេត្តកំពង់ចាម និងមិនទាន់ដឹងក្ដីប៉ុន្មានទេពេលនោះ។ នៅពេលខ្មែរក្រហមចូលមកក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រើខ្ញុំឲ្យរែកដីរហូតដល់ឆ្នាំរំដោះ១៩៧៩។ ខ្ញុំលើកទំនប់ ជីកស្រះ លើកភ្លឺស្រែ តាំងពីអាយុ ១៤ឆ្នាំមកម្ល៉េះ។ ចំណែកការបរិភោគវិញ ខ្ញុំទទួលបានអាហារ មួយថ្ងៃតែពីរពេលទេ គឺពេលព្រឹក និងល្ងាច ហើយអាហារដែលខ្ញុំទទួលបានក្នុងមួយពេលម្ដងៗ មានត្រឹមបបរមួយចានចង្កឹះសុទ្ធតែទឹក ព្រោះបបរមួយឆ្នាំងខ្ទះធំ ចុងភៅដាក់អង្ករតែពីរគីឡូកន្លះទេ។ ពេលនោះពិបាកវេទនាណាស់ យើងមិនដែលបានហូបឆ្អែតម្ដងណាឡើយ។ នៅរបបខ្មែរក្រហម គ្មានអ្វីធ្វើឲ្យយើងសប្បាសចិត្តទេ។ យើងមានតែទឹកភ្នែក បើនិយាយពីពោះមនុស្សវិញខៀវដូចពោះសត្វឈ្លើង។ បាយដែលយើងហូបមានតែផ្លែពោតក្រហម យកមកលាយនឹងបបរមកឲ្យយើងបរិភោគ ហើយថ្ងៃឡើងខ្ញុំឃ្លានពេកដើររកក្ដាមមកហូបជំនួសបាយ។ ចំពោះការរស់នៅវិញ យើងមិនដែលបានរស់ជួបជុំគ្នាទេ ម្ដាយឪពុក ទៅរស់នៅផ្សេង ហើយខ្ញុំទៅរស់នៅកន្លែងផ្សេង។ ខ្ញុំនៅតែក្នុងព្រៃ កណ្ដាលវាលកណ្ដាលថ្ងៃ ហាលខ្យល់ ដល់ពេលរដូវវស្សាចូលមកដល់ ទើបខ្មែរក្រហមចាប់ផ្ដើមធ្វើផ្ទះឲ្យរស់នៅជាក្រុម។ កុមាររាប់រយពាន់នាក់នៅមួយក្រុម ដោយខ្មែរក្រហមមិនបានឲ្យនៅជាមួយឪពុកម្ដាយទេ។ ប្រសិនបើហ៊ានតែជួបឪពុកម្ដាយយើង ដឹងតែមេកង ឬមេក្រុមវាយធ្វើបាបហើយ។ ខ្ញុំមិនធ្លាប់មេក្រុមវាយទេ ប៉ុន្តែក្មេងៗផ្សេងទៀតត្រូវមេកងវាយនៅនឹងមុខខ្ញុំតែម្ដង។ មេកងវាយក្មេងឡើងហើមមុខ បែកខ្មេចខ្មី ព្រោះមេកងយកគល់ឩសកំពុងតែឆេះមកវាយ ធ្វើឲ្យឆេះដៃ ឆេះជើងក្មេងៗរលោកសាច់អស់។ ក្រោយមកក្នុងឆ្នាំ១៩៧៩ ខ្ញុំ

ដឹងថា ខ្មែរក្រហមយកមនុស្សមកសម្លាប់នៅភ្នំប្រុស ភ្នំស្រី។ ខ្ញុំបានបាត់បង់ឪពុកមាម្នាក់ឈ្មោះ អ៊ំ សំ។ ខ្មែរក្រហមសម្លាប់ចោល ពេលគាត់បែកចេញពីភ្នំពេញទៅនៅខេត្តតាកែវ ដោយចោទគាត់ថាជាបណ្ឌិតទាហាន។

ក្រោយមក កងទ័ពវៀតណាមចូលមករំដោះ ខ្ញុំកំពុងតែរែកដីនៅចំផ្លូវរថក្រោះបរកាត់តែម្តង។ ខ្ញុំភ័យពេករត់ចង់ស្លាប់រហូតបានមកដល់ផ្ទះ។ គ្រាន់តែមកផ្ទះភ្លាម កងទ័ពវៀតណាមបានមកដល់តាមក្រោយដែរ តែកងទ័ពវៀតណាមមិនបានធ្វើអ្វីខ្ញុំទេ។ កងទ័ពវៀតណាមគ្រាន់តែសួររកកងទ័ពរបស់ខ្មែរក្រហមប៉ុណ្ណោះ។ ខ្ញុំក៏ឆ្លើយថា ខ្ញុំមិនដឹងថាកងទ័ពខ្មែរក្រហមមួយណាទេ ខ្ញុំដឹងថាកងទ័ពទាំងនោះចាកចេញទៅឆ្ងាយហើយ។ កងទ័ពវៀតណាម បានប្រាប់ឲ្យខ្ញុំនៅផ្ទះ ហើយក្រោយមកកងទ័ពវៀតណាមបានចាត់តាំងឲ្យខ្ញុំធ្វើមេភូមិមេឃុំ។ មេភូមិនិងមេឃុំ មិនមែនយើងចង់ធ្វើ ចេះតែបានធ្វើនោះទេ ទាល់តែកងទ័ពវៀតណាមចាប់ដាក់ឲ្យធ្វើទើបអាចធ្វើបាន។ ឪពុកមារបស់ខ្ញុំម្នាក់ ធ្វើជាមេភូមិរហូតដល់ស្លាប់។

ពេលរំដោះដំបូងៗ ខ្ញុំចាប់ផ្តើមធ្វើស្រែ ប៉ុន្តែពេលនោះយើងធ្វើស្រែរួមជួយគ្នាទៅវិញទៅមក ហើយដល់ពេលយើងបោកបែនស្រូវរួច ទើបយើងចាត់ចែងចែកស្រូវគ្នា។ ក្រោយមកឆ្នាំ១៩៨២ ខ្ញុំមករស់នៅតំបន់អូរស្វាយ។ ឪពុករបស់ខ្ញុំចាប់ផ្តើមធ្វើស្រែនៅឆ្នាំដំបូងបានផលរហូតដល់ ៤០០ប៉ោត។ ការធ្វើស្រែបានធ្វើឲ្យជីវភាពក្រុមគ្រួសាររបស់ខ្ញុំបានធូរធារមួយចំណែកដែរ។ មិនយូរប៉ុន្មាន ខ្ញុំក៏ចាប់ផ្តើមឈឺគ្រុនចាញ់។ ខ្ញុំឈឺរហូតដល់អស់ ២ឆ្នាំ ដោយមិនបានជួយអ្វីដល់ឪពុកម្តាយរបស់ខ្ញុំទេ។ នៅក្នុងឆ្នាំ១៩៨២ ដដែល ឪពុករបស់ខ្ញុំ ក៏ចាប់ផ្តើមចេញនេសាទដោយធ្វើលប ដើម្បីចុះទៅនេសាទត្រី។ នៅតំបន់អូរស្វាយនេះ សម្បូរត្រីណាស់។ ឪពុករបស់ខ្ញុំ ធ្វើលបយកទៅដាក់តែ ៤លបទេ ហើយមានត្រីខ្វាចូលលបរាល់យប់។ ក្នុងមួយយប់ យើងរកត្រីខ្វាបាន ២ ទៅ ៣ក្បាល ដែលក្នុងមួយក្បាលៗយ៉ាងហោចណាស់មានទំងន់ ៧គីឡូក្រាម។ បើត្រីខ្វាដែលធំជាងគេ មួយក្បាលមានរហូតដល់ ២៥គីឡូក្រាម។

ក្រោយមក ក្នុងឆ្នាំ ១៩៩៥ ដល់ឆ្នាំ ១៩៩៦ ទើបឪពុករបស់ខ្ញុំចាប់ផ្តើមមានទូកយកទៅនេសាទ។ យើងរកចំណូលបានគួរសមដែរជារៀងរាល់ថ្ងៃ ព្រោះប្រជាជនឡាវចូលមកទិញត្រីច្រើន។ ប្រជាជននៅតំបន់អូរស្វាយនេះ ភាគច្រើននេសាទត្រីចាប់ពីឆ្នាំ១៩៩៥ រហូតមកប៉ុន្តែបច្ចុប្បន្ននេះ យើងរកត្រីមិនបានទៀតទេ ទើបយើងនាំគ្នាចេញមកធ្វើចម្ការដំឡូង និងស៊ីឈ្នួលខ្លះ។ ទោះជាត្រីមិនសូវសម្បូរ ខ្ញុំនៅតែរកត្រីដដែលដើម្បីបានត្រីខ្លះៗមកហូបប្រចាំថ្ងៃ។ ខ្ញុំប្រើតែមង និងលបទេ ដើម្បីចាប់ត្រី តែប្រជាជនផ្សេងមួយចំនួននាំគ្នានេសាទខុសច្បាប់ ធ្វើឲ្យត្រីហិនហោចខ្ទេចខ្ទីគ្មានសល់។

បើប្រៀបធៀបការនេសាទពីមុន និងនេសាទបច្ចុប្បន្ន គឺពិបាកខ្លាំង ដោយសារតែការទប់ស្កាត់នេសាទខុសច្បាប់នៅមានកម្រិត។ សព្វថ្ងៃនេះ ពេលយើងយកមងទៅដាក់ ២ ទៅ ៣ដៃ យើងរកត្រីមិនចង់បានមួយសម្លផង។ មុខរបបនេសាទពីមុនមកអាចជួយផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់ខ្ញុំបានច្រើន តែមកដល់បច្ចុប្បន្ននេះ យើងរកមិនចង់បានហូបប្រចាំថ្ងៃផង។ ពេលខ្ញុំទៅនេសាទម្តងៗ ពិតជាមានការលំបាកណាស់។ ខ្ញុំទៅជួបតែអ្នកឆក់ត្រីធ្វើឲ្យមងរបស់ខ្ញុំមិនជាប់ត្រីសោះ ។

ការរស់នៅបច្ចុប្បន្ន មិនជាពិបាកអ្វីណាស់ណាទេ ព្រោះយើងធ្លាប់ឆ្លងកាត់នូវការលំបាកជាច្រើនមកហើយ។ ក្តីបារម្ភរបស់ខ្ញុំតាំងពីសាងសង់ទំនប់វារីអគ្គិសនីរួចមក ខ្ញុំសង្កេតឃើញថា ត្រីពីមួយឆ្នាំទៅមួយឆ្នាំ មានការថយចុះ រួមទាំងការនេសាទខុសច្បាប់កាន់តែកើនឡើង។ ចំណែកធនធានធម្មជាតិព្រៃលិចទឹកក៏ថយចុះដែរ។ ព្រៃលិចទឹកនៅតំបន់រ៉ាមសារ បាត់បង់ស្ទើរតែ ៨០ភាគរយទៅហើយ បើគិតមកដល់បច្ចុប្បន្ននេះ។ មូលហេតុដែលបណ្តាលឲ្យព្រៃលិចទឹកងាប់បែបនេះ គឺមកពីរបបទឹកមិនទៀតទាត់តាមធម្មជាតិ ។

ជាចុងក្រោយ ខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាល មន្ត្រីជលផល មន្ត្រីបរិស្ថាន និងស្ថាប័នដែលពាក់ព័ន្ធ សូមបន្ថែមនូវការទប់ស្កាត់បទល្មើសខុសច្បាប់នានា ដែលបានកើតនៅតំបន់រ៉ាមសារនេះ។ បើសិនជាទប់ស្កាត់បាននោះ ប្រជាជនយើងនឹងអាចអាស្រ័យផលបានពីធនធានទាំងនេះមកវិញ។

# ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដែនកំណត់នៃការសិក្សាស្រាវជ្រាវ គឺជាលក្ខខណ្ឌមួយចម្បងដែលជះឥទ្ធិពលលើសមត្ថភាពក្នុងការសង្ខេបពីលទ្ធផល និងការពិពណ៌នាបន្ថែមអំពីកិច្ចការស្រាវជ្រាវដើម្បីយកមកអនុវត្ត[២២]។ អំឡុងពេលដំណើរការគម្រោងស្រាវជ្រាវ ក្រុមរបស់យើងមានឧបសគ្គមួយចំនួនដែលធ្វើឲ្យមានការរាំងស្ទះចំពោះការអនុវត្តគម្រោង និងត្រូវការពេលវេលាបន្ថែមសម្រាប់ការសិក្សាឲ្យបានស៊ីជម្រៅជាងនេះ។ ភាគច្រើននៃឧបសគ្គរបស់យើង គឺជាការសហការគ្នានៅក្នុងក្រុម ពេលវេលាមានកំណត់ក្នុងការចុះស្រាវជ្រាវនៅមូលដ្ឋាន និងខ្វះបទពិសោធន៍ក្នុងការសរសេរកិច្ចការស្រាវជ្រាវ។ ក្រុមអ្នកស្ម័គ្រចិត្តរបស់យើងមានទីតាំងស្នាក់នៅឆ្ងាយពីគ្នា និងមានភាពមមាញឹកក្នុងការងារប្រចាំថ្ងៃ ដែលជាមូលហេតុមួយធ្វើឲ្យកិច្ចការស្រាវជ្រាវនេះ រអាក់រអួលបន្តិចបន្តួច។ ពេលវេលានៃការចុះទៅមូលដ្ឋានដើម្បីសិក្សាស្វែងយល់ពិតជាសំខាន់ណាស់ ហើយយើងមានឱកាសចុះមូលដ្ឋានបានតែម្តងប៉ុណ្ណោះក្នុងមួយខែ ថែមទាំងមានការរំខានពីអាកាសធាតុក្តៅខ្លាំងនៅក្នុងរដូវប្រាំងដែលអាចប៉ះពាល់ដល់សុខភាពក្នុងពេលបំពេញការងារ។ លើសពីនេះ ការសរសេរចងក្រងកិច្ចការស្រាវជ្រាវក៏ជាឧបសគ្គមួយសម្រាប់ក្រុមរបស់យើងដែលមិនសូវមានបទពិសោធន៍ក្នុងការសរសេរកន្លងមក។ យើងបានចំណាយពេលវេលាជាច្រើនរៀនសូត្របន្ថែមទៅលើចំណុចជាច្រើនឲ្យបានលម្អិតបំផុត ដើម្បីឲ្យកិច្ចការស្រាវជ្រាវមួយនេះសរសេរឡើងប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវទៅតាមក្បួនខ្នាត។ កង្វះឧបករណ៍បច្ចេកទេសដូចជា ម៉ាស៊ីនថត និងប្រដាប់ថតសំឡេងសម្រាប់ការផលិតវីដេអូ និងការថតសំឡេងពេលសម្ភាសឲ្យបានល្អក៏ជាផលលំបាកមួយសម្រាប់យើងដែរ។ ទោះបីជាយើងជួបឧបសគ្គយ៉ាងណាក៏ដោយ យើងមិនដែលមានចិត្តចង់បោះបង់គម្រោងស្រាវជ្រាវមួយនេះឡើយ ហើយបានប្រឹងប្រែងបញ្ចប់កិច្ចការស្រាវជ្រាវរបស់យើងបានទាន់ពេលវេលា។

២២ Dhanya Alex, “How to Present the Limitations of a Study in Research?,” Researcher. Life by Editage,August 29, 2023, https://researcher.life/blog/article/what-are-limitations-of-study-in-research/

# ការរៀនសូត្រអំពីកិច្ចការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «យុត្តិធម៌សម្រាប់ប្រជានេសាទ៖ ប្រជាជននេសាទលក្ខណៈគ្រួសារប្រឈមមុខនឹងជីវភាពប្រចាំថ្ងៃ» នៅតំបន់អូរស្វាយ យើងបានស្វែងយល់ដឹងអំពីរឿងរ៉ាវជាច្រើន មិនត្រឹមតែរឿងរ៉ាវទាក់ទងប្រធានបទការនេសាទត្រីនោះទេ ប៉ុន្តែយើងបានដឹងអំពីរឿងរ៉ាវប្រវត្តិសាស្ត្រសំខាន់ៗផ្សេងទៀត ជាពិសេសរឿងរ៉ាវឃោរឃៅដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម (១៩៧៥ ដល់ ១៩៧៩) នៅលើទឹកដីតំបន់អូរស្វាយ ដែលយើងគួរតែរៀនសូត្រឲ្យបានស៊ីជម្រៅបន្ថែមទៀត។

កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ដែលប្រព្រឹត្តទៅពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិតេជោ នៃទីបញ្ជាការដ្ឋានកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ បានថ្លែងសារដ៏មានអត្ថន័យបំផុតមួយ ដើម្បីក្រើនរំឭកដល់ស្ថាប័នរដ្ឋាភិបាលទាំងអស់ ទាំងយោធា និងស៊ីវិល ឲ្យគាំទ្រដល់ការងារអប់រំពីអំពើប្រល័យពូជសាសន៍សម្រាប់មនុស្សជំនាន់ក្រោយថា៖

*«ស្ថាប័នរដ្ឋាភិបាលទាំងអស់ ទាំងយោធា និង ស៊ីវិល ត្រូវតែគាំទ្រការងារអប់រំពីអំពើប្រល័យពូជសាសន៍សម្រាប់មនុស្សជំនាន់ក្រោយ។ យើងត្រូវតែធានាថា ការបង្រៀនប្រវត្តិសាស្ត្រ ត្រូវបានដាក់បញ្ចូលយ៉ាងត្រឹមត្រូវនៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋ និង ឯកជន ចាប់ពីអនុវិទ្យាល័យរហូតដល់សាកលវិទ្យាល័យ ហើយគ្រូបង្រៀនទាំងអស់របស់យើង អាចចូលរួមជាកម្លាំង ដើម្បីផ្សព្វផ្សាយការអប់រំពីអំពើប្រល័យពូជសាសន៍ នៅក្នុងសាលារៀនទូទាំងប្រទេស។ ការអប់រំពីអំពើប្រល័យពូជសាសន៍ មិនចាំបាច់កំណត់ត្រឹមតែមេរៀនប្រវត្តិសាស្ត្រនោះទេ។ យើងក៏អាចបញ្ចូលទៅក្នុងមុខវិជ្ជាគ្រប់ប្រភេទ ចាប់ពីសីលធម៌ និង អក្សរសាស្ត្រខ្មែរ រហូតដល់ការសិក្សាពីភាពជាអ្នកដឹកនាំ និង ការអភិវឌ្ឍជំនាញទន់ផ្សេងទៀតផងដែរ។ យើងក៏អាចស្វែងរកវិធីច្នៃប្រឌិតផ្សេងៗ ដើម្បីរៀបរាប់រឿងរ៉ាវពិបាកទាំងនេះ ទៅកាន់មនុស្សដែលមានវ័យ និង ជំនាន់ផ្សេងគ្នារួមមាន តាមរយៈសិល្បៈ មាតិកាឌីជីថល ឬ គំនូរជីវចល ជាដើម។*

*យើងចាំបាច់ត្រូវសង្កត់ធ្ងន់ថា កាតព្វកិច្ចលើកកម្ពស់ការអប់រំពីអំពើប្រល័យពូជសាសន៍ គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា មិនមែនតែរាជរដ្ឋាភិបាលម្នាក់ឯងនោះទេ។ សន្និសីទថ្ងៃនេះ គឺជាគំរូដ៏ប្រសើរនៃកិច្ចសហប្រតិបត្តិការល្អ និងសាមគ្គីភាពរវាងតួអង្គពាក់ព័ន្ធផ្សេងៗ។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលបានជួយរាជរដ្ឋាភិបាលក្នុងការដាក់បញ្ចូលការបង្រៀនអំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ ទៅក្នុងការអភិវឌ្ឍវិជ្ជាជីវៈ និងស្ថាប័ន និងសម្រាប់សកម្មភាពផ្សព្វផ្សាយក្នុងមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដោយប្រើប្រាស់ប្រវត្តិសាស្ត្រដើម្បីត្រិះរិះពិចារណា និងបំផុសគំនិត សម្រាប់អនាគតកម្ពុជា»* ។[២៣]

នៅក្នុងតំបន់អូរស្វាយ ប្រជាជនជាច្រើននាក់ទទួលរងភាពញាំញី និងបន្តរងរបួសស្នាមផ្លូវចិត្តពីសង្គ្រាម ហើយការសិក្សាពីប្រវត្តិសាស្ត្រផ្សារភ្ជាប់នឹងស្ថានភាពបច្ចុប្បន្នបែបនេះ គឺជាតម្រូវការចាំបាច់ក្នុងការ

២៣ សម្រង់ប្រសាសន៍របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ក្នុងពិធីបើកសន្និសីទលើកទី១ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ដែលប្រព្រឹត្តទៅពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិតេជោ នៃទីបញ្ជាការដ្ឋានកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ។

ស្វែងយល់ពីមូលហេតុ ដើម្បីកែលម្អសម្រាប់ពេលបច្ចុប្បន្ន និងអនាគតកាល។ «ការសិក្សាប្រវត្តិសាស្ត្រ គឺជាផ្នែកមួយដ៏សំខាន់ចំពោះចក្ខុវិស័យនៃការអប់រំ។ ប្រវត្តិសាស្ត្រអាចត្រូវបានសិក្សាដើម្បីដឹងគុណ និងត្រិះរិះពិចារណាលើគំនិតអតីតកាល មនុស្ស និងស្ថាប័ន។ ប្រវត្តិសាស្ត្រអាចចាក់គ្រឹះសម្រាប់ក្តីសង្ឃឹម ការបំផុសគំនិត និងញ្ញាតិសន្តាន ហើយប្រវត្តិសាស្ត្រអាចត្រូវបានប្រើប្រាស់ជាឧបករណ៍អប់រំ ដើម្បីពន្យល់ពីកំហុស ចំណុចខ្វះខាត និងអំពើអាក្រក់របស់សង្គម។ ប្រវត្តិសាស្ត្រ បង្ហំឲ្យប្រទេសនានាទទួលស្គាល់ទុក្ខវេទនាដែលកើតឡើងក្នុងនាមសាសនា វប្បធម៌ និងប្រទេស ហើយប្រវត្តិសាស្ត្របានបង្ហំឲ្យបុគ្គលម្នាក់ៗប្រឈមមុខនឹងភាពភ័យរន្ធត់ដែលអាចកើតមាននៅក្នុងសង្គមទាំងអស់»[២៤]។ សព្វថ្ងៃនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រឹងប្រែងរស់នៅប្រឈមមុខដោះស្រាយវិបត្តិអតីតកាលដែលនៅសេសសល់ពីសង្គ្រាមដោយខ្លួនឯង លើបញ្ហាសុខភាពជាចម្បង បញ្ហាផ្លូវចិត្តតាមរយៈការបែកបាក់សាច់ញ្ញាតិ និងក្តីអស់សង្ឃឹមនៅក្នុងជីវិតដោយមិនដឹងដោះស្រាយនឹងជីវភាពរស់នៅសព្វថ្ងៃយ៉ាងដូចម្តេច។ ទន្ទឹមនឹងនេះ ផលរំខានជាច្រើននៅក្នុងសហគមន៍ បានកើតឡើងជាបន្តបន្ទាប់ រួមមាន៖ ទី១ តាមរយៈគម្រោងនៃការអភិវឌ្ឍតាមដងទន្លេមេគង្គលើទំនប់វារីអគ្គិសនី និងទី២ ចំណាត់ការផ្លូវច្បាប់មិនសូវមានប្រសិទ្ធភាព ចំពោះការនេសាទខុសច្បាប់ដែលធ្វើឲ្យប្រជាជនស្លូតត្រង់ក្នុងភូមិទទួលរងផលប៉ះពាល់ដល់ជីវិតរស់នៅប្រចាំថ្ងៃ ។

តាមរយៈការសិក្សាស្វែងយល់ពីប្រជាជនរស់នៅក្នុងមូលដ្ឋានផ្ទាល់ យើងបានស្វែងរកឃើញពីផលប៉ះពាល់អំពីការនេសាទដែលកំពុងតែរំខានដល់ជីវិតរស់នៅសព្វថ្ងៃរបស់ប្រជាជនជាច្រើននាក់ ជាពិសេសប្រជាជនដែលរស់នៅតាមកោះទាំង ៨ ក្នុងស្រុកបុរីអូរស្វាយសែនជ័យ។ ការនេសាទខុសច្បាប់ទ្រង់ទ្រាយធំនៅតែមានជាបន្តបន្ទាប់ បណ្តាលឲ្យត្រីហិនហោចចំណែកឯចំណាត់ការផ្លូវច្បាប់តឹងតែងពេក ធ្វើឲ្យប៉ះពាល់ដល់ប្រជាជនរកត្រីមិនបាន ត្រឹមតែសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ ។



*អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះសម្ភាសអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកបុរីអូរស្វាយសែនជ័យ។ (រូបថត៖ ស្រេង លីដា)*

២៤ Youk Chhang, “Learning history is crucial to prevent mass atrocities in future world,” Khmer Times, October 20, 2023. https://www.khmertimeskh.com/501379229/learning-history-is-crucial-to-prevent-mass-atrocities-in-future-world/

# សេចក្តីសន្និដ្ឋាន

គម្រោងស្រាវជ្រាវ «**យុត្តិធម៌សម្រាប់ប្រជានេសាទ៖ អ្នកនេសាទជាលក្ខណៈគ្រួសារប្រឈមមុខនឹងជីវភាពប្រចាំថ្ងៃ**» នៅតំបន់អូរស្វាយ តាមដងទន្លេមេគង្គក្នុងប្រទេសកម្ពុជា បង្ហាញពីបញ្ហាប្រឈមចំពោះជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នកនេសាទ ដោយសារផលប៉ះពាល់ពីការសាងសង់ទំនប់វារីអគ្គិសនីនៅតែបន្ត ការនេសាទខុសច្បាប់ និងការអនុវត្តច្បាប់នេសាទមិនសូវមានប្រសិទ្ធភាព។ ក្រៅពីនេះ ការសិក្សាស្រាវជ្រាវទទួលបានព័ត៌មានប្រវត្តិសាស្ត្រផ្សេងៗបន្ថែមទៀតដែលមានសារសំខាន់សម្រាប់ក្មេងៗជំនាន់ក្រោយសិក្សារៀនសូត្របន្ថែម។ គម្រោងស្រាវជ្រាវនេះ បានធ្វើការសម្ភាសផ្ទាល់មាត់ជាមួយអ្នកភូមិជាច្រើននាក់ ក្នុងនោះយើងបានសម្រេចចិត្តជ្រើសរើសយកអ្នកភូមិចំនួន ៧នាក់ ដែលរស់នៅក្នុងតំបន់អូរស្វាយតាំងពីវ័យក្មេង។ យើងបានចាប់យកបទពិសោធន៍ និងទស្សនៈរបស់ប្រជាជនលើការវិវត្តន៍របស់តំបន់អូរស្វាយតាំងពីដើមមក ភាពសម្បូរបែបនៃធនធានធម្មជាតិ និងការបាត់បង់ ព្រមទាំងបទពិសោធន៍ជីវិតរបស់ប្រជាជនប្រចាំថ្ងៃ ។

សាវតាប្រវត្តិសាស្ត្ររបស់តំបន់អូរស្វាយ តាំងពីការចាប់ផ្តើមកសាងជាសហគមន៍ឡើងដោយ ព្រះបាទនរោត្តម សីហនុ ដល់របបខ្មែរក្រហម បង្ហាញពីសារសំខាន់ ដែលយើងត្រូវចូលរួមសិក្សាពីតំបន់អូរស្វាយឲ្យបានច្រើន។ វាមិនត្រឹមតែជួបបញ្ហាលើការអភិវឌ្ឍនោះទេ ប៉ុន្តែតំបន់អូរស្វាយបានប្រាប់រឿងរ៉ាវជាច្រើនពីអតីតកាល រួមមាន បញ្ហាព្រំដែន, សង្គ្រាម, ភាសា និងការប្រាស្រ័យទាក់ទងគ្នារវាងប្រជាជននៅតំបន់អូរស្វាយ និងប្រជាជនប្រទេសជិតខាង ។

យើងសង្ឃឹមថា កិច្ចការស្រាវជ្រាវរបស់យើងនឹងចូលរួមលើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រឈមនិងការអភិវឌ្ឍនរបស់ប្រជាជននៅតាមតំបន់អូរស្វាយបច្ចុប្បន្ន និងអតីតកាល។ កិច្ចការស្រាវជ្រាវនេះ ជាការលើកឡើងជាមតិយោបល់ដើម្បីកែលម្អដល់វិធានការការពារធនធានធម្មជាតិ ដូចជា ដោះស្រាយបញ្ហាទាក់ទងនឹងទំនប់វារីអគ្គិសនី ការបង្កើនការទប់ស្កាត់ការនេសាទខុសច្បាប់ ការដាំកូនឈើដែលលិចទឹកឡើងវិញ ការស្វែងរកដីដើម្បីដោះស្រាយដល់អ្នកភូមិដែលរស់នៅតាមកោះ និងការពិនិត្យមើលឡើងវិញទៅលើផលប៉ះពាល់ដល់ប្រជាជនដែលរកស៊ីនេសាទត្រីតាមលក្ខណៈគ្រួសារ។

# ឯកសារយោង


ការសាកសួរពីមតិយោបល់ប្រជាជនកំពុងរស់នៅក្នុងស្រុកបុរីអូរស្វាយសែនជ័យ ឆ្នាំ២០២៤

"ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម," មជ្ឈមណ្ឌលឯកសារកម្ពុជា, accessed May 31, 2024, https://www.dccam.org/homepage /health/rights-and-welfare-of-khmer-rouge-survivor/.

ខាន់ សុគុំមនោ, «អ្នកនិពន្ធ Abby Seiff៖ «យើងគួរនៅមានសង្ឃឹមថា បញ្ហាបឹងទន្លេសាបនឹងអាចប្រសើរឡើងវិញ,» វីអូអេ, ២២ មេសា ២០២២ ។ https://khmer.voanews.com/a/there-are-reasons-to-be-hopeful- if-things-come-together-well-and-if-mekong-river-countries-can-work-together-/6539538.html

Barney G. Glaser, The constant comparative method of qualitative analysis, 1965. CO2 Couching, "CHANGE YOUR SOCIAL CONTEXT, CHANGE YOUR LIFE," CO2 Couching, OCTOBER 24, 2013. https://co2coaching.com/social-context-changes-behavior/.

Courtney Gahan, « Chicago Style Citation Examples I Website, Book, Article, Video,» Scribbr, Published on July 25, 2018 Revised on April 9, 2024. https://www.scribbr.com/chicago-style/citation-examples/#:~:text=Author%20first%20name%20last%20name,%2C%20page% 20number (s).&text =Albert%20Einstein%2C%20The%20Meaning%20of,1923)%2C%2044%E2%80%9345.

Dhanya Alex, "How to Present the Limitations of a Study in Research?," Researcher. Life by Editage,August 29, 2023. https://researcher.life/blog/article/what-are-limitations-of-study-in-research/

"ALTHOUGH TWO MILLION WERE KILLED, FIVE MILLION SURVIVED TO TELL THEIR STORY," មជ្ឈមណ្ឌលឯកសារកម្ពុជា, accessed May 31, 2024. https://www.dccam.org/although-two-millions-were-killed-five-millions-more-survived-to-tell-their-story-the-perpetrators-of-these-crimes-also-survived-as-well/.

International Centre for Environmental Management (ICEM), Strategic Environmental Assessment of Hydropower on the Mekong Mainstream: a summary of the final Report, October, 2010, P.4. https://www.mrcmekong.org/assets/Publications/Consultations/SEA-Hydropower/SEA-FR-summary-13oct.pdf

Intralawan, Wood & Frankel, "Economic Evaluation of Hydropower Projects in the Lower Mekong Basin," OXFAM, March 2017, P.2.

Mekong River Commission For Sustainable Development, "People," MRC, 2022. https://www.mrcmekong.org/about/mekong-basin/people/

MRC (Mekong River Commission), State of the Basin Report, MRC, April 2010, P.31. https://www.mrcmekong.org/assets/Publications/basin-reports/MRC-SOB-report-2010full-report.pdf

NOVAsia Contributor, “The Mekong River – Environment and Economic Impacts of Dam Building in Southeast Asia”, NovAsia, January 12,2022. https://novasiagsis.com/the-mekong-river-environment-and-economic-impacts-of-dam-building-in-southeast-asia/.

របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ ប្រចាំខែមករា ឆ្នាំ ២០២៤ (ប្រភព៖ សាលាស្រុកបុរីអូរស្វាយសែនជ័យ)។

សម្រង់ប្រសាសន៍របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ក្នុងពិធីបើកសន្និសីទលើកទី១ស្តីពី "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍" ដែលប្រព្រឹត្តទៅពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិតេជោ នៃទីបញ្ជាការដ្ឋានកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ ។

Soukhaphon, Akarath, Ian G. Baird, and Zeb S. Hogan, The Impacts of Hydropower Dams in the Mekong River Basin: A Review, Water (Basel), 13, No. 3, p.2.
https://www.mdpi.com/2073-4441/13/3/265

Youk Chhang, “Learning history is crucial to prevent mass atrocities in future world,” Khmer Times, October 20, 2023. https://www.khmertimeskh.com/501379229/learning-history-is-crucial-to-prevent-mass-atrocities-in-future-world/

អ៊ុក សារបូរី,«ផលប៉ះពាល់ដោយគម្រោងសង់ទំនប់វារីអគ្គិសនីចំពោះពលរដ្ឋតាមដងទន្លេមេគង្គ,» វិទ្យុអាស៊ីសេរី,ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣។ https://www.rfa.org/khmer/news/environment/impact-of-environment-by-hydropower-dam-06052013041732.html

Patricia Leavy,“Oral History Understanding Qualitative Research,” Oxford University Press, 2011. https://global.oup.com/academic/product/oral-history-9780195395099?cc=us&lang=en&.

ឧក្រិដ្ឋកម្មបនវាតទីអនុត្តរភាពនិយមចិនប៉េកាំង និងបរវារ ប៉ុលពត អៀង សារី ខៀវ សំផន ក្នុងកំឡុងឆ្នាំ១៩៧៥-១៩៧៨ , ភ្នំពេញ, ១៩៨៣ (ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# កំណត់ចំណាំរបស់អ្នកស្ម័គ្រចិត្ត

ក្រុមអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចំនួន ៥នាក់ រួមមាន ស្រេង លីដា, យន់ ឃីម , យ៉ោន ចំរើន, លុច លេខ និង ស្រេង ករុណា   បានសហការគ្នាសិក្សាស្រាវជ្រាវលើប្រធានបទ «**យុត្តិធម៌សម្រាប់ប្រជានេសាទ៖ ប្រជាជននេសាទលក្ខណៈគ្រួសារប្រឈមមុខនឹងជីវិតប្រចាំថ្ងៃ**»។ កិច្ចការស្រាវជ្រាវនេះ ធ្វើឡើងនៅតាមដងទន្លេមេគង្គស្ថិតក្នុងស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ក្រោមការដឹកនាំដោយ អ៊ុន សុដាវី ចាប់ពីថ្ងៃទី១៥ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤។

ជាដំបូង ក្រុមអ្នកស្ម័គ្រចិត្តរបស់យើងខ្ញុំ សូមគោរពថ្លែងអំណរគុណដល់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និង អ្នកស្រី សូ ហ្វារីណា នាយិការងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់ឱកាស គំនិត និងថវិកាដល់ក្រុមអ្នកស្ម័គ្រចិត្តរបស់យើង សម្រាប់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ។ ប្រធានបទនេះមិនត្រឹមតែជាការស្រាវជ្រាវអំពីរឿងរ៉ាវដែលទាក់ទងទៅនឹងការនេសាទ និងផលប៉ះពាល់ដល់អ្នកនេសាទប៉ុណ្ណោះទេ ប៉ុន្តែក្រុមអ្នកស្ម័គ្រចិត្តរបស់យើងខ្ញុំ បានទទួលព័ត៌មានសំខាន់ៗជាច្រើនទៀតចេញពីការស្រាវជ្រាវ រួមមាន ប្រវត្តិនៃការកកើតនិងរឿងរ៉ាវដែលបានកើតឡើងនៅតំបន់អូរស្វាយតាមសម័យកាលនីមួយៗ ការកាន់កាប់របស់ក្រុមខ្មែរក្រហមនៅតំបន់អូរស្វាយ ជីវិតរស់នៅរបស់ប្រជាជន និងបញ្ហាប្រឈមជាច្រើនទៀតដែលប្រជាជនបានជួបប្រទះតាំងពីតំបន់អូរស្វាយកកើតឡើងរហូតមកដល់សព្វថ្ងៃ។ ព័ត៌មានទាំងអស់ដែលអ្នកស្ម័គ្រចិត្តយើងទទួលបាន ពិតជាមានសារសំខាន់ណាស់ក្នុងការសិក្សាស្វែងយល់ឲ្យបានទូលំទូលាយអំពីប្រធានបទរបស់យើង និងទុកសម្រាប់ក្មេងៗជំនាន់ក្រោយសិក្សាបន្តទៀតលើប្រធានបទស្រដៀងគ្នាឬខុសគ្នា ។

ជាបន្ទាប់ កិច្ចការស្រាវជ្រាវនេះ ក៏មិនអាចសម្រេចទៅបានប្រសិនបើគ្មានការជួយដឹកនាំរបស់ អ្នកគ្រូ អ៊ុន សុដាវី ប្រធានដឹកនាំក្រុមស្រាវជ្រាវរបស់ក្រុមអ្នកស្ម័គ្រចិត្តយើងតាំងពីដើមរហូតដល់បញ្ចប់គម្រោង។ ក្រុមអ្នកស្ម័គ្រចិត្តរបស់យើង ពិតជាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកគ្រូ អ៊ុន សុដាវី ដែលបានចំណាយពេលវេលាដឹកនាំក្រុមរបស់យើង ក្នុងដំណើរការសិក្សាស្រាវជ្រាវមួយនេះដោយមិនខ្លាចនឿយហត់ ថែមទាំងបានបង្រៀន ណែនាំ និងជួយសម្របសម្រួលដល់យើងអំពីរបៀបនៃការរៀបចំកម្រងសំណួរ ការស្រាវជ្រាវ ការសម្ភាស ការសរសេរ ការផលិតវីដេអូ របៀបទំនាក់ទំនងទៅកាន់ប្រជាជន និងអ្នកស្ម័គ្រចិត្ត ការធ្វើកិច្ចការងារជាក្រុម និងការចងក្រងឯកសារនានាដែលក្រុមអ្នកស្ម័គ្រចិត្តយើងមិនធ្លាប់បានធ្វើពីមុនមក។ ការសិក្សាស្រាវជ្រាវមួយនេះ ពិតជាមានអត្ថប្រយោជន៍ណាស់ចំពោះអ្នកអាន និងអ្នកស្រាវជ្រាវផ្សេងទៀត ព្រោះទិន្នន័យ ដែលក្រុមរបស់យើងប្រមូលបាន គឺជាទិន្នន័យដើម រួមមានការសម្ភាសប្រជាជនដែលបានឆ្លងកាត់រឿងរ៉ាវជាច្រើនជំនាន់ផ្ទាល់ និងទីតាំងប្រវត្តិសាស្ត្រ ជាដើម។

ដូចច្នេះ ក្រុមអ្នកស្ម័គ្រចិត្តរបស់យើង ស្វាគមន៍ និងលើកទឹកចិត្តដល់សិស្សានុសិស្ស និងអ្នកស្រាវជ្រាវទាំងឡាយណា ដែលមានមតិយោបល់ទៅលើកិច្ចការស្រាវជ្រាវរបស់យើង ឬមានបំណងចង់ស្រាវជ្រាវបន្ថែមលើកិច្ចការស្រាវជ្រាវចំពោះប្រធានបទនេះ ឬប្រធានបទស្រដៀងគ្នា ឲ្យបានច្រើននៅក្នុងស្រុកបុរីអូរស្វាយសែនជ័យ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងបំពេញបន្ថែមរាល់ចំណុចខ្វះខាតឲ្យគ្នាទៅវិញទៅមក។ ការសិក្សាស្រាវជ្រាវអំពីតំបន់អូរស្វាយ គឺជាកិច្ចការងារដ៏ចាំបាច់មួយដែលអ្នកស្រាវជ្រាវគួរតែធ្វើ ព្រោះតំបន់នេះមានទាំងបញ្ហាប្រវត្តិសាស្ត្រ ធម្មជាតិ ការអភិវឌ្ឍ និងជាតំបន់ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសឡាវ។ យើងសង្ឃឹមថាការសិក្សាស្រាវជ្រាវនេះ នឹងអាចជួយដល់អ្នកអានស្វែងយល់ដឹងអំពីទីតាំងប្រវត្តិសាស្ត្រនីមួយៗនៅតំបន់អូរស្វាយ  ព្រមទាំងនាំគ្នាចូលរួមការពារ ថែរក្សា និងផ្សព្វផ្សាយតំបន់នេះឲ្យបានទូលំទូលាយ។

# អំពីក្រុមអ្នកស្ម័គ្រចិត្ត

**១. ខ្ញុំឈ្មោះ យ៉ោន ចំរើន** ភេទប្រុស មានទីកន្លែងកំណើតនៅភូមិព្រៃល្វៀង ឃុំស្នួល ស្រុកក្រឡាញ់ ខេត្តសៀមរាប។ បច្ចុប្បន្ន ខ្ញុំកំពុងបន្តការសិក្សានៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាក្នុងក្រុងសៀមរាប ឆ្នាំទី២ លើមុខជំនាញទំនាក់ទំនងអន្តរជាតិ និងកំពុងបំពេញការងារក្នុងតួនាទីជាមន្ត្រីទំនាក់ទំនងនៅក្នុងអង្គការលើកកម្ពស់យុវជន នៅក្រុងសៀមរាប ។ ខ្ញុំចូលចិត្តដំណើរកំសាន្ត ស្រាវជ្រាវរៀនសូត្រនូវអ្វីដែលថ្មីៗ និងស្រលាញ់ចូលចិត្តការចែករំលែក។
ទំនាក់ទំនងតាមលេខទូរសព្ទ៖ ០៦៩ ៦៣៣ ០១៧និងអ៊ីម៉ែល៖ chamreun.nssp2020@gmail.com

**២. ខ្ញុំឈ្មោះ ឃន់ ឃីម** ភេទប្រុស មានទីកន្លែងកំណើតនៅភូមិក្បាលចាម ឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប។ បច្ចុប្បន្ន ខ្ញុំកំពុងបន្តការសិក្សានៅក្នុងសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ខេត្តសៀមរាប ជានិស្សិតឆ្នាំទី៣ ឆមាសទី២ លើមុខជំនាញនីតិសាស្ត្រ។ ខ្ញុំចូលចិត្តការផ្សងព្រេង ស្រាវជ្រាវលើប្រវត្តិសាស្ត្រ និងភូមិសាស្ត្រនយោបាយ ថែមទាំងចូលចិត្តស្តាប់ និងជជែកអំពីបញ្ហាក្នុងសង្គម ។
ទំនាក់ទំនងតាមលេខទូរសព្ទ៖ ០៩៦ ៨៨៤ ២៤៦១និងអ៊ីម៉ែល៖ vakhimkhun27@gmail.com

**៣. ខ្ញុំឈ្មោះ ស្រេង ករុណា** ភេទស្រី មានទីកន្លែងកំណើតនៅភូមិអូររុន ឃុំអូរស្វាយ ស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង។ បច្ចុប្បន្ននេះ ខ្ញុំគឺជាគ្រូបង្រៀនកិច្ចសន្យា និងមានគម្រោងរៀនបន្តថ្នាក់បរិញ្ញាបត្រ។ ខ្ញុំចូលចិត្តចូលរួមដំណើរទស្សនៈកិច្ច ការសិក្សាអ្វីដែលថ្មីៗ និងចូលចិត្តកសាងទំនាក់ទំនងជាមួយមិត្តរួមការងារជាដើម។
ទំនាក់ទំនងតាមលេខទូរសព្ទ៖ ០៩៧ ៨៥៩ ៤៧១២ និងអ៊ីម៉ែល៖ karanasreng@gmail.com

**៤. ខ្ញុំឈ្មោះ លុច លេខ** ភេទប្រុស ទីកន្លែងកំណើតរស់នៅភូមិរវៀងថ្មី ឃុំស្រែខ្វាវ ស្រុកអង្គរជុំ ខេត្តសៀមរាប។ សព្វថ្ងៃនេះ ខ្ញុំរស់នៅទីក្រុងសៀមរាបដើម្បីមកបំពេញការងារ ។ ខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រលើមុខជំនាញព័ត៌មានវិទ្យា នៅសាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ ហើយខ្ញុំកំពុងតែបំពេញការងារពេញម៉ោងក្នុងតួនាទីជា ប្រធានក្រុមរចនារូបភាព នៅក្នុងក្រុមហ៊ុនឯកជនមួយកន្លែង។ ខ្ញុំចូលចិត្តរៀនពីអ្វីដែលថ្មីៗ ស្រាវជ្រាវពីបច្ចេកវិទ្យា ស្រលាញ់ភាពច្នៃប្រឌិត ចូលចិត្តធម្មជាតិ និងចូលចិត្តដំណើរកម្សាន្ត ។
ទំនាក់ទំនងតាមលេខទូរសព្ទ៖ ០៧៨ ៣៦៨ ២៣១ និងអ៊ីម៉ែល៖ lekhluch171095@gmail.com

**៥. ខ្ញុំឈ្មោះ ស្រេង លីដា** ភេទប្រុស កើតនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៩ មានទីកន្លែងកំណើតនៅភូមិអូររុន ឃុំអូរស្វាយ ស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង។ បច្ចុប្បន្ននេះ ខ្ញុំរស់នៅភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ឪពុករបស់ខ្ញុំឈ្មោះ ស្រេង ទិត្យ ម្តាយឈ្មោះ នុត ស៊ីថុន( ស្លាប់ ) ហើយខ្ញុំមានបងប្អូន ៣នាក់ ស្រី ១នាក់ ។ ខ្ញុំជាកូនច្បងនៅក្នុងគ្រួសារ។ បច្ចុប្បន្ន ខ្ញុំកំពុងបន្តការសិក្សានៅសាកលវិទ្យាល័យបៀលប្រាយ ខេត្តស្ទឹងត្រែង ជានិស្សិតឆ្នាំទី១ ឆមាសទី២ លើមុខជំនាញ គ្រប់គ្រងទូទៅ។ ខ្ញុំចូលចិត្តសិក្សាស្រាវជ្រាវអ្វីដែលថ្មីៗ ចូលចិត្តស្វែងយល់ពីតំបន់ប្រវត្តិសាស្ត្រដែលផ្សារភ្ជាប់ជាមួយនឹងធម្មជាតិ និងចូលចិត្តដំណើរកម្សាន្ត ។
ទំនាក់ទំនងតាមលេខទូរសព្ទ៖ ០៧១ ២៤ ៣៥ ១៦២  និងអ៊ីម៉ែល៖ srenglyda7@gmail.com



*ក្រុមអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះបំពេញការងារនៅស្រុកបុរីអូរស្វាយសែនជ័យ។*
*(រូបថត៖ អ៊ុន សុដារី)*